**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ទំនើបកម្មរដ្ឋបាលនៃឃុំ សង្កាត់ នៅកម្ពុជា (២០០១-បច្ចុប្បន្ន)

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ កញ្ញា **ឌីម សូរិយា**
កញ្ញា **ជឿន ស្រីល័ក្ខ**

សាស្ត្រាចារ្យណែនាំ
លោក **ឡឿក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ ឌីម សូរិយា និងកញ្ញា ជឿន ស្រីល័ក្ខ ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី ១២នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា២០១៨-២០១៩។

**សូមធ្វើគារវកិច្ច និងកតញ្ញូតាធម៌ចំពោះ ៖**

លោកឪពុក **រិន រិទ្ធី** និងអ្នកម្តាយ **ឧក សារ៉ាវ**

លោកឪពុក **ម៉ូល ជឿន** និងអ្នកម្តាយ **អ៊ុន បុប្ផា**

- **លោកឪពុក និងអ្នកម្តាយ** ដែលមានគុណយ៉ាងធំធេងជាអនេកប្បការចំពោះរូបកូនដោយបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូន និងបានបញ្ជូនកូនឲ្យទៅសាលារៀនដើម្បីសិក្សារៀនសូត្រ ក្រេបជញ្ជក់យកនូវចំណេះដឹងដើម្បីរស់នៅប្រកបដោយកិត្តិយស ខ្ពង់ខ្ពស់ និងទទួលបានសេចក្តីថ្លៃថ្នូរនៅក្នុងសង្គម។

- **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** សាកលវិទ្យាធិការរង លោក លោកស្រីដែលជាសាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាងក្នុងការជួយឱ្យយើងខ្ញុំទាំងពីរ មានលទ្ធភាពងាយស្រួលក្នុងការសិក្សា និងដំណើរការរដ្ឋបាលផ្សេងៗកន្លងមកនេះ។

- **លោកសាស្ត្រាចារ្យ ឡើក ពិសោរ** ដែលបានជួយណែនាំ អប់រំបន្ថែម និងបានជួយជ្រោមជ្រែងនៅក្នុងដំណើរការការរៀបរៀងពីសារណាមួយនេះឡើង។ លោកសាស្ត្រាចារ្យក៏បានចំណាយពេលវេលាមានតម្លៃផ្ទាល់ខ្លួនដោយមិនខ្លាចការនឿយហត់ក្នុងការជួយជាការផ្តល់មតិយោបល់ ចង្អុលបង្ហាញត្រួសត្រាយពីវិធីសាស្ត្រផ្សេងៗជាច្រើននៅក្នុងការស្រាវជ្រាវរកឯកសារ បង្ហាញទិសដៅក្នុងការរុករកអ្វីដែលថ្មី ព្រមទាំងជួយកែលម្អនូវរាល់ចំណុចខ្វះខាត ក៏ដូចជាចំណុចខុសឆ្គងមួយចំនួន និងបានផ្តល់ជាអនុសាសន៍ល្អៗថ្មីៗដល់យើងខ្ញុំទាំងពីរ សម្រាប់តាក់តែងសៀវភៅនេះឡើងរហូតបានបញ្ចប់ទៅបានដោយជោគជ័យ។ បើមិនមានវត្តមានរបស់លោកសាស្ត្រាចារ្យ ពួកយើងទាំងពីរក៏មិនអាចសម្រេចបាននូវស្នាដៃដ៏ប្រពៃនេះឡើងបានដែរ។

- **លោក ជោរ ចន** អនុប្រធានក្រុមប្រឹក្សាផ្សារដើមថ្កូវនៃសង្កាត់ផ្សារដើមថ្កូវ ដែលបានជួយណែនាំពីដំណើរការនៃការអនុវត្តការងារនៅក្នុងសង្កាត់ផ្សារដើមថ្កូវ ព្រមទាំងជួយផ្តល់បន្ថែមនូវឯកសារដែលទាក់ទងនឹងសេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

គុណូបការៈដ៏ថ្លៃថ្លាទាំងនេះ ធ្វើឱ្យយើងខ្ញុំដឹងគុណ និងចងចាំជានិច្ចដែលមិនអាចបំភ្លេចបាន និងសូមប្រសិទ្ធពរជ័យ សូមលោកអ្នកទាំងអស់បានជួបប្រទះតែគុណបុណ្យព្រះរតនត្រ័យ

ដែលជាវត្ថុស័ក្តសិទ្ធិក្នុងលោកមានពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ ជាទីពឹងគ្រប់ពេលវេលាព្រម ទាំងពុទ្ធពរ ទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតពីយើងខ្ញុំ។

# អារម្ភកថា

ក្នុងនាមពួកយើងទាំងពីរជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាជំនាញ **រដ្ឋបាលសាធារណៈ** អស់រយៈពេលបួនឆ្នាំកន្លងទៅនេះ យើងឃើញថា ពួកយើងទាំងពីរទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើន ដែលពួកយើងបានខិតខំសិក្សាស្រាវជ្រាវកន្លងមក ដោយសារតែការខិតខំប្រឹងប្រែងបែបនេះហើយ ទើបពួកយើងទទួលបានលទ្ធផលល្អជាទីគាប់ចិត្ត។ ហេតុនេះហើយ ទើបពួកយើងសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយដែលទាក់ទងទៅនឹងវិស័យសាធារណៈ ដោយផ្តោតសំខាន់ទៅលើ **"ទំនើបកម្មនៃរដ្ឋបាល ឃុំ សង្កាត់នៅកម្ពុជា (២០០១-បច្ចុប្បន្ន)"**។ ដូច្នេះពួកយើងទាំងពីរមានគោលបំណងក្នុងការរៀបចំចងក្រងជាសារណាមួយក្បាលនេះឡើង ដើម្បីទុកជាស្នាដៃជំនួយដល់ការសិក្សាស្រាវជ្រាវរបស់ សិស្ស និស្សិតជំនាន់ក្រោយៗទៀត មិនថាចំពោះតែលើកិច្ចការស្រាវជ្រាវផ្សេងៗ ឬការអានសិក្សាស្វែងយល់នោះទេ។

ចំពោះប្រធានមួយនេះ យើងខ្ញុំបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវ ក៏ព្រោះតែចង់ដឹងចង់ស្វែងយល់ពីបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងស្ថាប័នរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ទាំងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ នីតិវិធី ការរៀបចំ និងការប្រព្រឹត្តទៅ សមាសភាព សមត្ថកិច្ច និងការត្រួតពិនិត្យលើដំណើរការផ្សេងៗ។ បើយើងក្រឡេកទៅមើលស្ថានភាពបច្ចុប្បន្ននៅកម្ពុជាសព្វថ្ងៃយើងឃើញថា រដ្ឋបាលឃុំ សង្កាត់ គឺទាមទារការធ្វើទំនើបកម្មឲ្យសមស្របទៅនឹងបរិបទសង្គមដើម្បីទទួលបាននូវភាពងាយស្រួលក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ មិនតែប៉ុណ្ណោះ ការធ្វើទំនើបកម្មនេះក៏ជាកត្តាមួយដែលជួយជម្រុញឲ្យប្រទេសកម្ពុជាយើងមានការអភិវឌ្ឍ រីកចម្រើន លូតលាស់កាន់តែខ្លាំងទៅលើការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើទំនើបកម្មនេះផងដែរ ក៏ទាមទារឲ្យមានការធ្វើវិមជ្ឈការដើម្បីជួយសម្រួលដល់ដំណើរការក្នុងការអនុវត្តការងារផ្សេងៗក៏ដូចជាជួយពន្លឿនដល់ការបម្រើសេវាធារណៈរបស់ស្ថាប័នរដ្ឋបាល។

ដូចនេះពួកយើងទាំងពីររំពឹងយ៉ាងមុតមាំថា ស្នាដៃមួយនេះនឹងជួយចង្អុលបង្ហាញ និងបំភ្លឺសម្រាប់ការសិក្សាស្រាវជ្រាវរបស់ប្អូនៗជំនាន់ក្រោយ។ ចំណេះដឹងទាំងនេះ គឺជាទ្រព្យមួយយ៉ាងសំខាន់សម្រាប់មនុស្សម្នាក់ៗ យើងគ្រប់គ្នាត្រូវតែខិតខំក្រេបជញ្ជក់ដើម្បីជាស្ពានសម្រាប់ជីវិតរស់នៅ មានចំណេះដឹងប្រៀបបីដូចជាមានអ្វីៗគ្រប់យ៉ាង ព្រោះថាយើងអាចប្រើវាក្នុងការធ្វើឲ្យចេញជាលទ្ធផលគួរជាទីគាប់ចិត្តនិងផលប្រយោជន៍ជាច្រើនទៀត។

# មាតិកា

**សេចក្តីផ្តើម** ..... ១

## ជំពូក ១

## ទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ផ្នែក ១ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឃុំ សង្កាត់ ..... ៣

កថាខណ្ឌ ១ អង្គការគ្រប់គ្រង ..... ៣

១.១.១. ក្រុមប្រឹក្សា ..... ៣

១.១.២. ប្រធានក្រុមប្រឹក្សា ..... ៤

១.១.៣. សមត្ថកិច្ច ..... ៤

១.១. ៤. ការត្រួតពិនិត្យ ..... ៩

១.១.៤.១. ការត្រួតពិនិត្យលើមនុស្ស ..... ៩

១.១.៤.២. ការត្រួតពិនិត្យលើសេចក្តីសម្រេច ..... ១១

កថាខណ្ឌ ២ ការប្រព្រឹត្តទៅរបស់ឃុំ សង្កាត់ ..... ១២

កថាខណ្ឌ ៣ ការផ្តល់សេវាឃុំ សង្កាត់ ..... ១៥

១.៣.១. ការផ្តល់សេវាសាធារណៈរដ្ឋបាល ..... ១៥

១.៣.២. ការផ្តល់សេវានគរបាលរដ្ឋបាល ..... ១៦

១.៣.៣. ការផ្តល់សេវានៃនគរបាលយុត្តិធម៌ ..... ១៧

## ជំពូក ២

## ទំនើបកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

ផ្នែក ១ ការរៀបចំ និងការអនុម័តថវិកាឃុំ សង្កាត់ ..... ២៤

កថាខណ្ឌ ១ ការរៀបចំថវិកាឃុំ សង្កាត់ ..... ២៤

២.១.១. ប្រភពចំណូលរបស់ឃុំ សង្កាត់ ..... ២៤

២.១.២. ប្រភពចំណាយរបស់ឃុំ សង្កាត់........................................................................................២៥

២.១.៣. ប្រតិទិននៃការរៀបចំថវិកា......................................................................................... ២៦

កថាខណ្ឌ ២ ការអនុម័តថវិកាឃុំ សង្កាត់ ............................................................................. ២៨

កថាខណ្ឌ ៣ ការគ្រប់គ្រងការចំណាយ.................................................................................២៩

ផ្នែក ២ ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់សម្រាប់ឃុំ សង្កាត់.............................................៣១

ផ្នែក ៣ សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់ .......................................៣៣

**សេចក្តីសន្និដ្ឋាន** ............................................................................................................ ៣៥

**អនុសាសន៍** .......................................................................................................................៣៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

តាមអត្ថបទរបស់លោក JEAN-MICHEL FILIPPI ស្តីពី Le Phum, cet inconnu ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១២ នៅក្នុងរបកគំហើញនៃប្រទេសកម្ពុជា នៅពេលបារាំងមកដល់ប្រទេសខ្មែររដ្ឋបាលឃុំមិនទាន់មាននៅឡើយ។ ប៉ុន្តែមានមជ្ឈមណ្ឌលនៃផលប្រយោជន៍មូលដ្ឋានដែលមិនបានលេចរូបរាងច្បាស់លាស់នោះទេ។ ផ្ទុយទៅវិញ វៀតណាមមានរចនាសម្ព័ន្ធឃុំរួចជាស្រេចទៅហើយ ដែលមានការរៀបចំដ៏ល្អតាំងពីយូរមុនបារាំងមកដល់ម្ល៉េះ។ ឃុំវៀតណាម ជាឃុំដែលមានលក្ខណៈធម្មជាតិបំផុត ហើយជាកោសិកាដ៏សំខាន់នៃជីវភាពរដ្ឋបាល និងសង្គម។

ចាប់ពីឆ្នាំ ១៩០៨ ១៩០៩ ១៩២៥ បារាំងបានរៀបចំរដ្ឋបាលឃុំរបស់ខ្មែរ។ នេះជាការធ្វើទំនើបកម្មលើកដំបូងនៃរដ្ឋបាលឃុំខ្មែរ។ ប៉ុន្តែដោយសារកត្តានយោបាយ ហិរញ្ញវត្ថុ និងធនធានមនុស្សមិនអនុគ្រោះ រឿងនេះមិនបានជោគជ័យនោះទេ។ ទើបតែមកដល់ឆ្នាំ ២០០១ ឃុំ សង្កាត់ត្រូវបានធ្វើវិមជ្ឈការសារជាថ្មីឡើងវិញ ហើយជាកម្មវត្ថុនៃការធ្វើកំណែទម្រង់ជាបន្តបន្ទាប់ទាំងផ្នែកគ្រប់គ្រងរដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។ កំណែទម្រង់នេះស្ថិតនៅក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល នោះគឺនយោបាយវិសហមជ្ឈការ និងវិមជ្ឈការ។ គណកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ជាស្ថាប័នស្នូលរបស់ក្រសួងមហាផ្ទៃក្នុងការជម្រុញគោលនយោបាយនេះ។

ការធ្វើទំនើបកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរដ្ឋបាលឃុំ សង្កាត់ ចាប់តាំងពីដើមសតវត្សទី ២០ រហូតមកដល់បច្ចុប្បន្ន ជាកម្មវត្ថុនៃនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅទីនេះ យើងនឹងលើកយកមកសិក្សាតែ ទំនើបកម្មនៃរដ្ឋបាលឃុំ សង្កាត់ ចាប់តាំងពីឆ្នាំ ២០០១ ដល់បច្ចុប្បន្នប៉ុណ្ណោះ។ តើទំនើបកម្មមានន័យយ៉ាងដូចម្តេច? ហើយតើទំនើបកម្មរដ្ឋបាលឃុំ សង្កាត់ផ្តោតទៅលើអ្វីខ្លះ?

ទំនើបកម្មរដ្ឋបាល មានន័យថាធ្វើឲ្យប្រសើរឡើងក្នុងការចូលទៅប្រើសេវាសាធារណៈរបស់អ្នកប្រើប្រាស់ ការធ្វើសនិទានកម្មនៃរចនាសម្ព័ន្ធរដ្ឋ ការជម្រុញនៃប្រព័ន្ធជ្រើសរើសមន្ត្រីរាជការផ្អែកលើសមត្ថភាព ទំនើបកម្មនៃការគ្រប់គ្រងធនធានមនុស្ស ក៏ដូចជាការពង្រឹងសមត្ថភាពនៃការរៀបចំបង្កើតការដាក់ឲ្យអនុវត្តន៍ ការវាយតម្លៃ និងការត្រួតពិនិត្យនៃនយោបាយសាធារណៈដែលជាជម្រើសនយោបាយ និងរដ្ឋាភិបាល។ វាត្រូវតែផ្អែកលើរដ្ឋបាលមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈស្វ័យប្រវត្តិកម្មនៃនីតិវិធីរដ្ឋបាល ការធ្វើឲ្យទៅជាលក្ខណៈផ្ទៃក្នុងនៃវប្បធម៌នៃការគ្រប់គ្រងផ្អែកលើលទ្ធផល[1]។

ទំនើបកម្មនៃរដ្ឋបាលមានគោលដៅច្រើនៈ

- ធ្វើឲ្យកាន់តែប្រសើរឡើងការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាល ហើយនិងប្រសិទ្ធភាពនៃសកម្មភាពរដ្ឋបាល និងគុណភាពនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ គឺត្រូវឆ្លើយតបទៅនឹងការរិះ

[1] www.Fonctionpublique.gouv.sn

គន់ដែលតែងតែកើតមានឡើងទៅលើ ការគ្មានប្រសិទ្ធភាពនៃយន្តការរដ្ឋបាល ការយឺតយ៉ាវនៃរដ្ឋបាល និងថ្លៃដើមរបស់រដ្ឋបាល។ តើទស្សនៈនេះ ទំនើបកម្មនៃរដ្ឋបាលមានផ្លូវច្រើនដែលត្រូវធ្វើតាម៖ ការអភិវឌ្ឍនៃការវាយតម្លៃនៃនយោបាយសាធារណៈ (ការកំណត់ឡើងវិញនៃបរិមាណនៃសកម្មភាពរបស់រដ្ឋ ការស៊ើរើជាទូទៅនៃនយោបាយសាធារណៈ កំណែទម្រង់ថវិកាជាមួយនឹងការដាក់ឲ្យអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ និងការគ្រប់គ្រងឲ្យបានប្រសើរនៃធនធានមនុស្សរបស់រដ្ឋ។

ទំនើបកម្មនៃសកម្មភាពសាធារណៈទាក់ទងទៅនឹងសកម្មភាព ០៣ (បី) ជាអាទិភាព៖ ការធ្វើឲ្យសាមញ្ញនៃសកម្មភាពរដ្ឋបាល ការពន្លឿននៃរយៈពេលបណ្តោះអាសន្ននៃការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថល (Digital) និងការវាយតម្លៃសាធារណៈ។

ដូច្នេះកាន់តែធ្វើឲ្យប្រសើរឡើងវិញនូវស័ក្តិសិទ្ធភាពនៃរដ្ឋបាល និងធ្វើយ៉ាងណាឲ្យមានការសន្សំសំចៃប្រាក់កាសសាធារណៈ។ ទំនើបកម្មត្រូវបានរីកចម្រើនឡើងនៅក្នុងបរិបថនៃហិរញ្ញវត្ថុសាធារណៈដែលត្រូវបានធ្វើកំណែទម្រង់ (ថវិកាកម្មវិធី)។

- ទំនើបកម្មនៃរដ្ឋបាលក៏មានគោលបំណងផងដែរ គឺធ្វើឲ្យកាន់តែប្រសើរឡើងទំនាក់ទំនងរវាងរដ្ឋបាល និងរាស្ត្រប្រជា ហើយដូច្នេះសេវាដែលត្រូវបម្រើជូនប្រជាពលរដ្ឋ។ រឿងនេះប្រព្រឹត្តទៅតាមការទទួលរបស់អ្នកប្រើប្រាស់ឲ្យបានប្រសើរឡើង ការធ្វើសាមញ្ញកម្មនៃទម្រង់បែបបទ និងនីតិវិធីរដ្ឋបាល (ឧទាហរណ៍៖ ច្រកចេញចូលតែមួយ) ការពង្រីករដ្ឋបាលអេឡិចត្រូនិច (E-Administration) ការពង្រឹងសិទ្ធិរបស់ប្រជាពលរដ្ឋប្រឈមនឹងរដ្ឋបាល (ឧទាហរណ៍៖ សិទ្ធិចូលទៅពិគ្រោះឯកសាររដ្ឋបាល) និងពង្រឹងនយោបាយតម្លាភាព។
- ការធ្វើសាមញ្ញកម្មនៃការរៀបចំរដ្ឋបាលរបស់រដ្ឋ ជាពិសេសលុបចោល «អង្គការឥតប្រយោជន៍» ហើយកាត់បន្ថយចំនួន អគ្គនាយក អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលកណ្តាល។

តើទំនើបកម្មនៃរដ្ឋបាលឃុំ សង្កាត់ចាប់តាំងពីឆ្នាំ ២០០១ មកទាក់ទងនៅនឹងអ្វីខ្លះ?

ដើម្បីយល់ច្បាស់ពីរឿងនេះ ដំបូងយើងនឹងសិក្សាពីទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សង្កាត់ (ជំពូក ១) បន្ទាប់មកទៀត យើងនឹងលើកយកទំនើបកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ សង្កាត់មកសិក្សា(ជំពូក២)។

# ជំពូក ១
# ទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# ជំពូក ១

# ទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ការធ្វើទំនើបកម្មនេះ ផ្តោតទៅលើការធ្វើសនិទានកម្មនៃរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមរយៈច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ ២០០១។

## ផ្នែក ១ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ នឹងរៀបចំឲ្យមានរចនាសម្ព័ន្ធមួយខុសពីរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ ១៩០៨ ១៩២៥ ខុសគ្នាទាំងសមាសភាពនៃថ្នាក់ដឹកនាំ រចនាសម្ព័ន្ធ បេសកកម្ម។

### កថាខណ្ឌ ១ អង្គការគ្រប់គ្រង

#### ១.១.១. ក្រុមប្រឹក្សា

យោងតាមព្រះរាជប្រកាសឆ្នាំ១៩២៥ ក្រុមប្រឹក្សាឃុំ កាលនោះមានឈ្មោះថា ក្រុមជំនុំចាស់ទុំ។ ក្រោយមកទៀតក្រុមជំនុំចាស់ទុំនេះហៅត្រឹមតែ ក្រុមជំនុំឃុំប៉ុណ្ណោះ។ ក្រុមជំនុំមានសមាសភាពជាមេឃុំ ជំទប់រាជា (ជំទប់លេខ១) ជំទប់សេនា (ជំទប់លេខ២) ជំទប់ភក្តី (ជំទប់លេខ៣) ជំទប់ស្នេហា (ជំទប់លេខ៤) និងមានជំទប់បម្រុង ០២ (ពីរ) ទៀតគឺ ជំទប់លេខ៥ និងជំទប់លេខ៦។

សង្កាត់ទើបនឹងត្រូវបានបង្កើតឡើងនៅសម័យសង្គមរាស្ត្រនិយម។ ដូច្នេះរដ្ឋបាលឃុំ សង្កាត់ចាប់ផ្តើមមានអាទិភាពពីពេលនោះមក។

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ ឃុំ សង្កាត់ មានក្រុមប្រឹក្សាមួយដែលកើតចេញពីការបោះឆ្នោតជាសកលសម្រាប់អាណត្តិ ០៥ ឆ្នាំ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លោកទី០១ បានប្រព្រឹត្តទៅនៅឆ្នាំ២០០២។ ក្រុមប្រឹក្សានេះមានសមាជិកប្រែប្រួលពី ០៥ ដល់ ១១ រូប អាស្រ័យលើកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ។

ក្រុមប្រឹក្សាឃុំ សង្កាត់ មានប្រធានម្នាក់ដែលជាមេឃុំចៅសង្កាត់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នឹងយកជាការបានលុះត្រាតែមានពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងមូលចូលរួម។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការបោះឆ្នោតអនុម័ត ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសម្រេចបញ្ហាណាមួយដូចខាងក្រោម ៖

- អនុម័តលើគម្រោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគម្រោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកម្រៃសេវាផ្សេងៗ
- អនុម័តបញ្ហាផ្ទៃក្នុង និងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។ ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីការបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ។

### **១.១.២. ប្រធានក្រុមប្រឹក្សា**

ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើស ចេញបេក្ខជនលេខរៀង លើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិ របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ មានជំទប់ចៅសង្កាត់រង ០២ (ពីរ) រូបជាជំនួយការ។ ហើយជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួល សម្លេងឆ្នោតលំដាប់ទី ២។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣។

### **១.១.៣. សមត្ថកិច្ច**

សមត្ថកិច្ច គឺជាអំណាចគតិយុត្តិដែលច្បាប់ទទួលស្គាល់ចំពោះឃុំ សង្កាត់ ក្នុងការធ្វើសកម្មភាពរបស់ខ្លួន ក្នុងការសម្រេចកិច្ចការរបស់ខ្លួន។

បើយោងតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ សមត្ថកិច្ចរបស់ឃុំ សង្កាត់ មិនទាន់ត្រូវបានកំណត់ដោយរបៀបជាក់លាក់នោះទេ។ ក្នុងន័យនេះ ក្រសួងមហាផ្ទៃកំពុងធ្វើកំណែទម្រង់ជា

បន្តបន្ទាប់ដោយសហការជាមួយនឹងក្រសួងនានាធ្វើយ៉ាងណាឲ្យក្រសួងទាំងនោះ ក៏ដូចជារដ្ឋបាលថ្នាក់ជាតិដែរ ផ្ទេរឲ្យបានជាក់លាក់នៅសមត្ថកិច្ចបន្ទាប់បន្សំរបស់ខ្លួនទៅឲ្យរដ្ឋបាលឃុំ សង្កាត់។

ឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ (មាត្រា ៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានា នៅក្នុងក្របខណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួន។

ដីកាឃុំ សង្កាត់ ត្រូវធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំចៅសង្កាត់។

រដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួន នូវដីកាដែលបានសម្រេចរួចហើយ។

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។

ដីកាឃុំ សង្កាត់ មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលជាព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលជាព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ ឃុំ សង្កាត់សាមី និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ឃុំ សង្កាត់ មានសមត្ថកិច្ចផ្សេងៗជាច្រើន៖

- ក្នុងការអភិវឌ្ឍឃុំ សង្កាត់៖ ឃុំ សង្កាត់ ទទួលបាននូវមូលនិធិមួយសម្រាប់ការអភិវឌ្ឍរបស់ខ្លួន។ មាត្រា ២ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ ចែងថា មូលនិធិមានគោលបំណងធ្វើឲ្យឃុំ សង្កាត់ អាចរ៉ាប់រងទទួលខុសត្រូវជាទូទៅលើការងាររដ្ឋបាលមូលដ្ឋាន និងជម្រុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋានស្របទៅនឹងមាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ធនធានសរុបនៃមូលនិធិត្រូវបែងចែកជាពីរសមាសភាគ៖ សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១ភាគ៣ នៃធនធានមូលនិធិសរុប។ សមាសភាគអភិវឌ្ឍន៍មូលដ្ឋានមិនត្រូវតិចជាង ២ភាគ៣ នៃធនធានមូលនិធិសរុប (មាត្រា ១២ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីមូលនិធិឃុំ សង្កាត់)។

- វិស័យហិរញ្ញវត្ថុ៖ ឃុំ សង្កាត់ អនុម័តលើគម្រោងថវិកាឃុំ សង្កាត់។ គម្រោងថវិកាត្រូវរៀបចំឡើង ក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងមានជំនួយការពីគណៈកម្មាធិការកសាង និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃទី៣១ ខែតុលា។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិកាតាមផ្នែក និងតាមប្រភេទនីមួយៗ។

មេឃុំ ចៅសង្កាត់ ត្រូវធានាឲ្យបានមានការចូលរួមពីសាធារណៈជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកា តាមរយៈវិធានការទាំងឡាយដូចខាងក្រោម៖

- គម្រោងថវិកា ត្រូវតែប្រកាសផ្សាយជាសាធារណៈ យ៉ាងតិច ២សប្តាហ៍ មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបើកចំហដល់សាធារណៈដែលចាប់អារម្មណ៍លើការពិនិត្យគម្រោងថវិកានេះ
- ប្រជាពលរដ្ឋ ត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសម្រេចលើគម្រោងថវិកា
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបង្កើតនូវយន្តការផ្សេងៗ ដើម្បីជម្រុញឲ្យមានការចូលរួមពីសាធារណៈជនលើកិច្ចការមូលដ្ឋាន។

មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនគម្រោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងឲ្យបានមុនថ្ងៃទី ៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់។

គម្រោងថវិកាត្រូវភ្ជាប់ជាមួយឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- របាយការណ៍សង្ខេបស្តីពី មូលដ្ឋានក្នុងការរៀបចំចំណូល និងចំណាយ ព្រមទាំងកម្រិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តនៃឆ្នាំដំណើរការ
- តារាងសង្ខេប នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ប្រសិនបើមាន

កំណត់ហេតុ ស្តីពីកិច្ចប្រជុំអនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាឲ្យបានមុនថ្ងៃទី៣០ ខែវិច្ឆិកា។

ការត្រួតពិនិត្យ អនុលោមភាពត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោម៖

១-ទម្រង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំថវិកា

២-តុល្យភាពថវិកា និងការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ

៣-លក្ខខណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ដែលទទួលបាន

៤-ការគ្រោងឥណទានថវិកាទៅគោលការណ៍ចំណាយចាំបាច់

៥-តម្រូវការថវិកាវិនិយោគ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការរបស់ឃុំ សង្កាត់។

ប្រសិន បើគម្រោងថវិកាត្រូវបានបំពេញតាមលក្ខខណ្ឌនៃការត្រួតពិនិត្យអនុលោមភាពដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ត្រូវបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនមេឃុំចៅសង្កាត់។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារ ដែលមានហត្ថលេខាសង្ខេបរបស់ អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ។

អភិបាលខេត្ត ក្រុង ត្រូវចម្លងជូនសេក្តីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង។

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា អភិបាលខេត្តក្រុងត្រូវជូនដំណឹងបន្ទាន់ជាលាយលក្ខណ៍អក្សរដល់មេឃុំចៅសង្កាត់ដោយបញ្ជាក់ពី មូលហេតុហើយណែនាំដល់មេឃុំ ចៅសង្កាត់ឲ្យអនុវត្តវិធានការកែតម្រូវ។

មេឃុំ ចៅសង្កាត់ ត្រូវត្រួតពិនិត្យកែគម្រោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ អនុម័តក្នុងរង្វង់ ១៥ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាលខេត្ត ក្រុង។

បន្ទាប់ពីការពិភាក្សាមេឃុំចៅសង្កាត់ផ្ញើគម្រោងថវិកាកែតម្រូវជូនអភិបាលខេត្ត ក្រុងបញ្ជាក់ទទួលស្គាល់។

ប្រសិនបើ មេឃុំចៅសង្កាត់ខកខានមិនបានបញ្ជូនគម្រោងថវិកាដែលបានពិនិត្យឡើងវិញដល់អភិបាលខេត្ត ក្រុង ក្នុងរង្វង់មួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងខាងលើ ឬថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតបបានទៅនឹងការត្រួតពិនិត្យអនុលោមភាព ពេលនោះ អភិបាលខេត្ត ក្រុង មានសិទ្ធិចាត់វិធានការកែសម្រួលចាំបាច់ មុនពេលបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា។ អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនដល់មេឃុំ ចៅសង្កាត់ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ។

- វិស័យពន្ធដារៈ ឃុំ សង្កាត់ កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកម្រៃសេវាផ្សេងៗ។ ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ។ ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធនៃការជួល។ ក្នុងករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់។ ប្រភេទ កម្រិត និងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់។

បន្ថែមលើសមត្ថកិច្ចទាំងនេះ មេឃុំចៅសង្កាត់ ក៏មានសមត្ថកិច្ចដែលទាក់ទងជាបេសកកម្មជាប្រពៃណីមួយចំនួនៈ

- ការរក្សាសណ្តាប់ធ្នាប់សាធារណៈតាមរយៈនៃអំណាចនគរបាលរបស់ខ្លួន។
- អត្រានុកូលដ្ឋាន
- មុខងារបោះឆ្នោត
- ការផ្តល់សេវាសាធារណៈចាំបាច់
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- អនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។
- ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើតសមត្ថកិច្ច និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្តន៍។ ប្រតិភូកម្មខាងលើនេះត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។

ឃុំ សង្កាត់ ត្រូវគោរពព្រំដែនសមត្ថកិច្ចរបស់ខ្លួន។ លោក Odilon និយាយថាវិមជ្ឈការអាចធ្វើឡើងដោយច្បាប់ គ្មានច្បាប់ គឺគ្មានវិមជ្ឈការ ហើយក៏គ្មានវិមជ្ឈការណាទៅហួសពីច្បាប់ដែរ។

មាត្រា ៤៥ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ កំណត់ពីព្រំដែននេះ។

រដ្ឋបាលឃុំ សង្កាត់ គ្មានអំណាចសម្រេចលើវិស័យទាំងឡាយដូចខាងក្រោមៈ

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារប្រទេស
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស

- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ ពីរ ឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឲ្យមានការសម្រុះសម្រួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ។

### ១.១. ៤. ការត្រួតពិនិត្យ

#### ១.១.៤.១. ការត្រួតពិនិត្យលើមនុស្ស

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោមៈ
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈឹមណាមួយ

សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៨៤ នៃច្បាប់នេះ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងមូលត្រូវរំសាយ។

សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាពត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមិនគោរពតាមបទប្បបញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

វិន័យរួមមានៈ

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែក ឬទាំងអស់នូវប្រាក់ឧបត្ថម្ភ។
- វិន័យដែលតម្រូវឲ្យកាត់មួយផ្នែក ឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចមានចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់។

ក្នុងករណីបានអនុវត្តរូបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់ អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួស តាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា ១៦ នៃច្បាប់នេះ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សា ឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឲ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តន៍រូបភាពវិន័យខាងលើនេះ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឲ្យដឹកនាំកិច្ចប្រជុំខាងលើពុំមានសិទ្ធិអនុម័តឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសម្រាប់ធ្វើការតាមដាន និងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ ដើម្បីៈ

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាច និងការបំពេញតួនាទី ភារកិច្ចរបស់ឃុំ សង្កាត់ នីមួយៗ
- ពិនិត្យមើលការវិវត្តអំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍ និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាច និងការបំពេញតួនាទីភារកិច្ច។

ក្នុងការតាមដាន ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចរំលែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខណ្ឌ ឲ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ។

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឲ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមលក្ខខណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសលិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុង និងដីកាឃុំ សង្កាត់។

តាមការតាមដាន ត្រួតពិនិត្យ និងធ្វើអន្តរាគមន៍រួមមានការងារៈ

- ស៊ើបអង្កេត និងវាយតម្លៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ

- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ។

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់។

ស្មៀនឃុំ សង្កាត់ តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយឃុំ សង្កាត់ និងធនធាននិវន្តភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់។

ស្មៀនឃុំ សង្កាត់ ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើររបស់មេឃុំ ចៅសង្កាត់អនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**១.១.៤.២. ការត្រួតពិនិត្យលើសេចក្តីសម្រេច**

ដីកាឃុំ សង្កាត់ មានប្រសិទ្ធភាពអនុវត្តន៍តែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។

ដីកាឃុំ សង្កាត់ មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈភាពដាច់ខាត។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃៈភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់ សាមុី និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

អភិបាលខេត្ត ក្រុង មិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជម្រើសនៃការចំណាយដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រៅពីពិនិត្យលើលក្ខខណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព។

មេឃុំ ចៅសង្កាត់ ត្រូវត្រួតពិនិត្យកែគម្រោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរង្វង់ ១៥ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាលខេត្ត ក្រុង។

ក្នុងករណីមិនមានការចុះសម្រុងគ្នារវាងមេឃុំ ចៅសង្កាត់ ជាមួយអភិបាលខេត្ត ក្រុង មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនករណីនេះ ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីត្រួតពិនិត្យសម្រេច។ សេចក្តីសម្រេច របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាត់ទុកជាការសម្រេចចុងក្រោយ។

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខណ្ឌទី១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផល និងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ច

ដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំ និងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឲ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខណ្ឌឲ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ។

ការបើធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ ណាធ្វើសកម្មភាពនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះឡើងវិញ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

**កថាខណ្ឌ ២ ការប្រព្រឹត្តទៅរបស់ឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់មានតួនាទី ភារកិច្ច របៀបរបបធ្វើការងារ និងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងនាកដ្ឋានចំណុះ។ ការលើកកម្ពស់ប្រសិទ្ធភាពការងារដឹកនាំរបស់អគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីធ្វើជាសេនាធិការជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ពិសេសគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ[2]។ ការសម្របសម្រួល ការតម្រង់ទិសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបានថ្នាក់រដ្ឋបាលនីមួយៗបំពេញតួនាទី មុខងារស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានដទៃទៀត ព្រមទាំងសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនៅក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

[2] មាត្រា ២ នៃអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល មានតួនាទីធ្វើជាសេនាធិកាជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ផ្អែកតាមតួនាទីខាងលើនេះ អគ្គនាយកដ្ឋានរដ្ឋបាល មានភារកិច្ចដូចតទៅៈ

- សិក្សា និងលើកយោបល់ក្នុងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- រៀបចំប្រព័ន្ធគាំទ្រ និងសម្របសម្រួលទៅលើការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងលើកអានុសាសន៍អំពីការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- រៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការបំពេញតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការសម្របសម្រួលក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំប្រព័ន្ធ និងនីតិវិធីសម្រាប់ធ្វើការសម្របសម្រួល និងដោះស្រាយវិវាទរដ្ឋបាលដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការរៀបចំប្រព័ន្ធ និងនីតិវិធីសម្រាប់គាំទ្រដល់ការសម្របសម្រួល និងដោះស្រាយវិវាទនៅមូលដ្ឋាន។
- គ្រប់គ្រងសកម្មភាពការងាររបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន ច្រកទ្វារកំពង់ផែរសមុទ្រ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការសម្របសម្រួល និងគាំទ្រនៅក្នុងការរៀបចំ ការគ្រប់គ្រង និងការអនុវត្តគម្រោងកម្មវិធីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងការរៀបចំ និងការអនុវត្តគម្រោងនានាដែលលើកកម្ពស់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយអភិវឌ្ឍន៍ទីក្រុង និងទីប្រជុំជននានា។

- សហការគាំទ្រ និងតាមដានដំណើរការនៃការផ្ទេរធនធានថវិកាឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ត្រួតពិនិត្យនីត្យានុកូលភាពទៅលើដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- លើកសំណើកែសម្រួលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានា ដែលផ្ទុយនឹងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ។
- សិក្សា ពិនិត្យ និងលើកយោបល់ពាក់ព័ន្ធនឹងការបង្កើត ការលុបចោល ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការកំណត់ឈ្មោះរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការលុបចោល ឬការបង្កើតភូមិ។
- ណែនាំលើការងារគ្រប់គ្រង និងការប្រើប្រាស់ត្រានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- សម្របសម្រួលលើសំណើសុំបង្កើត និងចុះបញ្ជីគណបក្សនយោបាយ ព្រមទាំងការបំពេញមុខងារពាក់ព័ន្ធគណបក្សនយោបាយស្របតាមការកំណត់របស់ច្បាប់។
- សម្របសម្រួលលើសំណើសុំចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងតាមដាន ត្រួតពិនិត្យការអនុវត្តស្របតាមលក្ខន្តិកៈនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។
- បំពេញការងារពាក់ព័ន្ធនឹងមន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។
- សហការរៀបចំ និងដាក់ឲ្យអនុវត្តន៍ ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ន ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការរៀបចំប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស និងផែនការបណ្តុះបណ្តាល អប់រំ កសាងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
- និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំបែបបទផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមច្បាប់កំណត់។
- រៀបចំ និងគ្រប់គ្រងសំណុំឯកសារ និងទិន្នន័យមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ សមាជិកក្រុមប្រឹក្សា និងបុគ្គលិកនៅករដ្ឋបាលថ្នាក់ក្រោមជាតិ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ កៀរគរប្រភពធនធាន និងមូលនិធិពីដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រ និងអភិវឌ្ឍន៍កម្មវិធី និងគម្រោងនានាសម្រាប់គាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

- រៀបចំ និងអនុវត្តន៍ផែនការសកម្មភាព និងថវិការបស់អគ្គនាយកដ្ឋានរដ្ឋបាល។
- ធ្វើសេចក្ដីរាការណ៍អំពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាលតាមការកំណត់។
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[3]។

**កថាខណ្ឌ ៣ ការផ្ដល់សេវាឃុំ សង្កាត់**

ឃុំ សង្កាត់ផ្ដល់សេវាសាធារណៈពីរប្រភេទធំៗ៖ សេវាសាធារណៈរដ្ឋបាលដែលជាកាតព្វកិច្ចរបស់ឃុំ សង្កាត់ក្នុងការផ្ដល់តាវកាលិកផ្នែកសង្គម ពោលគឺការធ្វើសកម្មភាពបម្រើប្រយោជន៍របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់ និងការរក្សាសណ្ដាប់ធ្នាប់សាធារណៈដែលជាបេសកកម្មរបស់នគរបាលបុស្ដិ៍រដ្ឋបាលឃុំ សង្កាត់។

**១.៣.១. ការផ្ដល់សេវាសាធារណៈរដ្ឋបាល**

តម្លៃសេវារដ្ឋបាលដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ រួមមានពីរប្រភេទ៖ ប្រភេទទី១ ត្រូវបានកំណត់ជាតម្លៃអតិបរមា និងប្រភេទទី២ ត្រូវបានកំណត់ជាតម្លៃជាក់លាក់ដូចមានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។ ក្នុងការកំណត់តម្លៃអនុគ្រោះ ចំពោះប្រជាពលរដ្ឋដែលមានប័ណ្ណក្រីក្រដែលបញ្ជាក់ទទួលស្គាល់ដោយមេឃុំចៅសង្កាត់។ ពាក្យស្នើសុំសេវារដ្ឋបាល និងត្រូវផ្ដល់ជូនដោយមិនយកកម្រៃ។ រាល់សំណុំបែបបទនៃការផ្ដល់សេវារដ្ឋបាលមិនតម្រូវឲ្យបិទតែមប្រ៏សារពើពន្ធឡើយ។ តម្លៃអតិបរមានៃសេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចកែប្រែបានដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកែប្រែតម្លៃអតិបរមានេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានសិទ្ធិចេញដីកាកែប្រែតម្លៃសេវារដ្ឋបាលជាក់ស្ដែងសម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អនុលោមតាមការកែប្រែតម្លៃអតិបរមានៃសេវារដ្ឋបាល ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ឬផ្អែកតាមកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

តម្លៃសេវារដ្ឋបាលនៅសង្កាត់ផ្សារដើមថ្កូវៈ

១- **ការងារអត្រានុកូលដ្ឋាន** មានដូចជាៈ សំបុត្រកំណើត, សំបុត្របញ្ជាក់កំណើត (បិទតែមប្រ៏លើពាក្យសុំ), សេចក្ដីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត, ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍(បិទតែមប្រ៏

[3] មាត្រា ៩ នៃអនុក្រឹត្យលេខ ២៦៩ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ

លើពាក្យសុំ), សំបុត្រអាពាហ៍ពិពាហ៍ (ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ), សំបុត្រអាពាហ៍ពិពាហ៍ (ជនបរទេស ជាមួយពលរដ្ឋខ្មែរ), សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍, សំបុត្រមរណៈភាព (ក្នុងរយៈពេល ១៥ ថ្ងៃ), សំបុត្រមរណៈភាព (ហួសរយៈពេល ១៥ថ្ងៃ ក្នុងមួយឆ្នាំ) និងសេចក្តីចម្លងសំបុត្រមរណៈភាព មិនត្រូវបានគិតតម្លៃនៃសេវារដ្ឋបាលនោះទេ។

២- **ការងារចេញលិខិតអនុញ្ញាត** មានៈ លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ និងលិខិតបញ្ជាក់ទីលំនៅ មិនគិតកម្រសៃសេវា, លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ តម្លៃសេវារដ្ឋបាល **៤ ០០០ រៀល**, លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី **១០ ០០០រៀល**សម្រាប់តម្លៃសេវារដ្ឋបាល, លិខិតបញ្ជាក់មាយាទ តម្លៃសេវារដ្ឋបាល **៥ ០០០រៀល**, លិខិតបញ្ជាក់កិរិយាមាយាទ តម្លៃសេវារដ្ឋបាល **៥ ០០០រៀល**, លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប, លិខិតបញ្ជាក់តបណ្តាយអគ្គិសនី តម្លៃសេវា **៥ ០០០រៀល**, លិខិតបញ្ជាក់តបណ្តាញទឹកស្អាត តម្លៃសេវា **៥០០០រៀល**, លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ **១០ ០០០រៀល** សម្រាប់តម្លៃសេវារដ្ឋបាល, លិខិតផ្ទះជួលបន្ទប់ស្នាក់នៅ មានតម្លៃសេវារដ្ឋបាល **៥ ០០០រៀល** និងបញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) **៥ ០០០រៀល សម្រាប់តម្លៃសេវារដ្ឋបាល**

### ១.៣.២. ការផ្តល់សេវានគរបាលរដ្ឋបាល

មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា ឃុំ សង្កាត់មានតួនាទីភារកិច្ចរៀបចំសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។ សណ្តាប់ធ្នាប់សាធារណៈមាននិយមន័យពីរ គឺនិយមន័យតាមន័យសម្ភារៈ និងជាលក្ខណៈខាងក្រៅ សម្តៅដល់ការចេញវិធានការធានាសន្តិសុខសាធារណៈ ភាពស្ងប់ស្ងាត់សាធារណៈ និងសុខមាលភាពសាធារណៈ។ សន្តិសុខសាធារណៈ គឺវិធានការទាំងឡាយណាដែលធានាការពារអាយុជីវិតរបស់មនុស្សដូចជា វិធានការឆែកឆេររកអាវុធជាតិផ្ទុះនៅតាមដងផ្លូវសាធារណៈ វិធានការហាមមិនឲ្យជះទឹកក្នុងពេលបុណ្យចូលឆ្នាំប្រពៃណីយជាតិ វិធានការហាមមិនឲ្យយកអាវុធជាតិផ្ទុះចូលក្នុងសាលារៀនជាដើម។ ភាពស្ងប់ស្ងាត់សាធារណៈសម្តៅលើវិធានការទាំងឡាយណាដែលមានគោលបំណងទប់ស្កាត់ ឬហាមមិនឲ្យមានបញ្ចេញសម្លេងដែលធ្វើឲ្យប៉ះពាល់ដល់អ្នកជិតខាង ជាពិសេសការបញ្ចេញសម្លេងនៅតាមទីសាធារណៈ ឧទាហរណ៍ ការហាមមិនឲ្យជេរបញ្ចោរគ្នានៅតាមទីសាធារណៈ ការហាមមិនឲ្យបើកបរទោចក្រយានយន្តដោយមានបំពង់ស៊ីម៉ាំគ្មានសំបុកទប់សម្លេង ការហាមមិនឲ្យចាក់វិទ្យុ ធុងបាសដែលបញ្ចេញសម្លេងប៉ះពាល់ដល់អ្នកជិតខាង។ល។ សុខមាលភាពសាធារណៈ ឬភាពស្អាតស្អំសាធារណៈសម្តៅលើវិធានការទាំងឡាយណាដែលមានគោលបំណងធានាបាននូវអនាម័យទាំងក្នុងការរស់នៅ និងក្នុងចំណីអាហារ។

និយមន័យទីពីរនៃសណ្តាប់ធ្នាប់សាធារណៈផ្អែកលើៈ វិធានការទាំងឡាយណាសម្តៅធានាការពារសេចក្តីថ្លៃថ្នូររបស់បុគ្គលជាមនុស្សដូចជា វិធានការហាមមិនឲ្យបញ្ចាំងភាពយន្ត ឬការសម្តែងនៅតាមទីសាធារណៈដោយយកមនុស្សតឿទៅលេងសើច ទោះជាមានព្រមព្រៀងពីមនុស្សតឿទាំងនោះក៏ដោយ។ វិធានការសម្តៅធានាការពារសីលធម៌ដ៏ល្អរបស់សង្គមក៏ជាសណ្តាប់ធ្នាប់សាធារណៈដែរ ឧទាហរណ៍ ការហាមមិនឲ្យបញ្ចាំងខ្សែភាពយន្តអាសអាភាស ប្រើភាសាអាសគ្រាម បទចម្រៀងអសីលធម៌មួយចំនួន។ល។ វិធានការសម្តៅប្រឆាំងបុគ្គលខ្លួនឯងដូចជា វិធានការបង្ខំឲ្យពាក់មួកសុវត្ថិភាពនៅពេលបើកទោចក្រយានយន្ត វិធានការបង្ខំឲ្យពាក់ខ្សែក្រវាត់ពេលបើកបរយានយន្ត ការហាមមិនឲ្យធ្វើអត្តឃាត។ល។

និយមន័យនេះអាចប្រែប្រួលទៅតាមលំហ និងពេលវេលា។

ក្រៅពីនិយមន័យទាំងពីរខាងលើ និយមន័យសម្ភារៈដែលផ្អែកលើពាក្យបីម៉ាត់ សន្តិសុខសាធារណៈ ភាពស្ងប់ស្ងាត់សាធារណៈ សុខមាលភាពសាធារណៈ និងនិយមន័យរីកសាយចេញពីពាក្យបីម៉ាត់នេះ ឃុំ សង្កាត់នៅមានបេសកកម្មជានគរបាលយុត្តិធម៌ទៀតផង។

### ១.៣.៣. ការផ្តល់សេវានៃនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌អនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពមានៈ

សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតមានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយឺតយ៉ាវរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ។

នាឱកាសសមិទ្ធីញរំលឹកខួបអនុវស្សាវីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិជាតិកម្ពុជានាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាង**ភូមិ ឃុំមានសុវត្ថិភាព** ដើម្បីលើកកម្ពស់ និងជម្រុញចលនាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមអានុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យក**ភូមិ ឃុំមានសុវត្ថិភាព** ធ្វើជាគោលនយោបាយអាទិភាពមួយសម្រាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯក

ជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគត់មត់ល្អនៅគ្រប់ភូមិ ឃុំទូទាំងប្រទេស។

ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗ៖

១- បន្តកសាងនិងពង្រឹងសេចក្តីសុខសុវត្ថិភាពជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើតល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែប្រសើរថែមទៀត។

២- បំផុសឲ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត **គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព**។

ភូមិ ឃុំមានសុវត្ថិភាព គឺភូមិ ឃុំដែលមានលក្ខណៈសម្បត្តិ ប្រាំ យ៉ាង៖

១- គ្មានសមត្ថភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២- គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣- គ្មានអំពោះអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤- គ្មានក្មេងទំនើង

៥- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ដើម្បីឲ្យលក្ខណៈសម្បត្តិទាំងនោះទទួលបានជោគជ័យគឺត្រូវមានវិធានការដូចខាងក្រោម៖

១- ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន។

២- ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ ឃុំ សង្កាត់ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣- ចាត់វិធានការលុបបំបាត់រាល់អំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា[4]។

៤- ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាពដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ[5]។

៥- ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់ងាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តន៍ទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន។

ផែនការសកម្មភាពមាន៖

១- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តន៍ឲ្យបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តន៍គោលនយោបាយ**ភូមិ ឃុំមានសុវត្ថិភាព** ក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន[6]។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ។

២- នគរបាលប៉ុស្តិ៍រដ្ឋបាលមានតួនាទីយ៉ាងសំខាន់ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកម្លាំងស្នូលពិតប្រាកដនៃចលនាការពារ «**ភូមិ ឃុំមានសុវត្ថិភាព**» និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ៖

- ត្រូវរៀបចំឲ្យមានក្របខណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ។
- ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការនិងសិទ្ធិអំណាចព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល[7]។

[4] ផែនការសកម្មភាពលេខ ០២៣ ផ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

[5] សារាចរណ៍លេខ ០៤ ស.រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ ន.ណ.ន ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០ផ.ក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង។

[6] សេចក្តីណែនាំ លេខ ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ។

- ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សម្ភារៈសម្រាប់បម្រើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ។
- ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍ នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភពក្នុងករណីមានសភាពការណ៍ដោះស្រាយ។
- ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមាសមត្ថកិច្ចនានាដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំសង្កាត់ភូមិ។
- ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនាភូមិ ឃុំមានសុវត្ថិភាព។
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវ៖
- ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរនគរបាលរដ្ឋបាលឃុំ សង្កាត់ជាប្រចាំ។ ជាមួយនេះគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជាឲ្យអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលបុស្តិ៍រដ្ឋបាលឃុំ សង្កាត់ នៅពេលមានបល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់។
- មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋានដោយត្រូវយកភូមិធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋានក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយ ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសរក្សាសុវត្ថិភាពភូមិ ឃុំ។

ក្រោមការសម្របសម្រួលរបស់រដ្ឋបាលឃុំ សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅតាមភូមិនីមួយៗ ឬកម្រងភូមិត្រូវរៀបចំឲ្យមានវេទិការសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ ឃុំ**។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស[8]។ ក្នុងវេទិការ

[7] មេរៀនដកស្រង់ពីក្រុមការងារ កាអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍។

[8] ផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ «**ចលនាប្រជាការពារ**» លេខ ០៣៨ផក ចុះថ្ងៃទី ០៣ ខែវិច្ឆិកាឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ។

នេះត្រូវធ្វើលារដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង។ ក្នុងករណីដោះស្រាយមិនបានត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ។

ក្រសួងមហាផ្ទៃក៏បានអំពាវនាវដូចខាងក្រោម៖

- ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួនចេញនូវការណែនាំលើមន្ត្រី អង្គភាពក្រោមឱវាទរបស់ខ្លួន ដើម្បីសហការលើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព។
- ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជនស ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធផលរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព។
- ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទសម្រាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនីមួយៗ សម្តៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយមពុំពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគម្រូក្នុងការអនុវត្តគោលនយោបាយ «ភូមិ ឃុំមានសុវត្ថិភាព»[9]។

ការចាត់តាំងអនុវត្តមានដូចខាងក្រោម៖

១- ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាកជាតិ ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ដឹកនាំ និងចាត់ដឹងអនុវត្តគោលនយោបាយ**ភូមិ ឃុំមានសុវត្ថិភាព**។

២- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួនត្រូវរៀបចំឲ្យមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយកភូមិជាគោលដៅ ដើម្បីសហការអនុវត្តន៍គោលនយោបាយ**ភូមិ ឃុំមានសុវត្ថិភាព**។

៣- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ «**ភូមិ ឃុំមានសុវត្ថិភាព**» ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់នីមួយៗ។

---

[9] សារាចរណ៍ណែនាំលេខ០០១ ស.រ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ធិញខយបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ១៦ ឧសភា១៩៩៥។

៤- គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និងលើកទិសដៅបន្តក្នុងរយៈពេល ០១ ត្រីមាសម្តង។ សមាសភាពចូលរួមក្នុងអង្គប្រជុំ គឺអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលសម្រេច។

៥- ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែសម្រួលផែនការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពនេះឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និងចាត់តាំងអនុវត្តជាទូទៅ។

៦- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមាក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុស និងពិនិត្យបូកសរុប វាយតម្លៃលក្ខណៈសម្បត្តិរបស់**ភូមិ ឃុំមានសុវត្ថិភាព**។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គលដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត។

៧- អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុត្រូវធ្វើគម្រោងថវិកា មធ្យោបាយ សម្ភារៈ បម្រើដល់ការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពនេះ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោកនយោបាយ**ភូមិ ឃុំមានសុវត្ថិភាព**នេះ ក្រសួងមហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមអនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធផលដែលអាចធ្វើបាន ដើម្បីទទួលជោគជ័យក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង[10]។

បេសកកម្មរបស់នគរបាលយុត្តិធម៌ គឺនគរបាលយុត្តិធម៌ជាជំនួយរបស់អំណាចតុលាការ។ នគរបាលមានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

សមាសភាពរបស់នគរបាលយុត្តិធម៌មាន:

១- មន្ត្រីនគរបាលយុត្តិធម៌

២- ភ្នាក់ងារនគរបាលយុត្តិធម៌

៣- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លួន។

---

[10]ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំ មានសុវត្ថិភាព» របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

ការសម្របសម្រួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

ព្រះរាជអាជ្ញាមានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជាការ និងភ្នាក់ងារសាធារណៈដទៃទៀត) នៃក្រមនេះ កាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌។

កាលណាអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រស៊ើបសួរ។

ការត្រួតពិនិត្យលើនគរបាលយុត្តិធម៌ គឺត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌[11]។

---

[11] មាត្រា ៥៦, ៥៧,៥៨ និងមាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៧

# ជំពូក ២
# ទំនើបកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

# ជំពូក ២
# ទំនើបកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

ថវិកាឃុំ សង្កាត់ ជាលិខិតគតិយុត្តិដែលគ្រោង និងអនុញ្ញាតចំណុល និងចំណាយដោយផ្អែកលើមូលដ្ឋានឆ្នាំ។ ឆ្នាំថវិការបស់ឃុំ សង្កាត់ ចាប់ផ្ដើមថ្ងៃទី០១ ខែមករា និងនៅថ្ងៃទី៣១ ខែធ្នូ។ ថវិកាឃុំ សង្កាត់ ត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់ឃុំ សង្កាត់ដោយមិនគិតដល់ប្រភពដើម ឬចរិលក្ខណៈឡើយ។ ថវិកាឃុំ សង្កាត់ត្រូវឆ្លុះរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ (មាត្រា ៣ អនុក្រឹត្យលេខ ២៦)។

## ផ្នែក ១ ការរៀបចំ និងការអនុម័តថវិកាឃុំ សង្កាត់

### កថាខណ្ឌ ១ ការរៀបចំថវិកាឃុំ សង្កាត់

ថវិកាឃុំ សង្កាត់ត្រូវបានរៀបចំឡើងជាពីរផ្នែក៖ ផ្នែកទី១ ចំណូល និងចំណាយចរន្ត។ ផ្នែកទី២ ចំណូល និងចំណាយមូលធន (មាត្រា ៤ អនុក្រឹត្យលេខ ២៦)។

### ២.១.១. ប្រភពចំណូលរបស់ឃុំ សង្កាត់

អតិរេកក្នុងផ្នែកទី១ ត្រូវបានប្រើប្រាស់ជាគុណប្រយោជន៍ក្នុងផ្នែកទី២។ ចំណូលមូលធនមិនត្រូវបានប្រើប្រាស់សម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយចរន្តលើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក។

ចំណូលចរន្តចែកចេញជា ៥ ប្រភេទ៖

ប្រភេទ១ ចំណូលពន្ធមូលដ្ឋាន

ប្រភេទ២ ចំណូលមិនមែនសារពើពន្ធ

ប្រភេទ៣ ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សម្រាប់រដ្ឋបាលទូទៅ

ប្រភេទ៤ ចំណូលពីការអនុវត្តមុខងារភ្នាក់ងារ

ប្រភេទ៥ ចំណូលចរន្តផ្សេងៗ (មាត្រា ៦ អនុក្រឹត្យលេខ ២៦)។

ចំណូលមូលធនចែកចេញជា ៤ ប្រភេទ៖

ប្រភេទ១ ចំណូលមូលននិធិបម្រុងដូចមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ។

ប្រភេទ២ ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សម្រាប់អភិវឌ្ឍន៍មូលដ្ឋាន

ប្រភេទ៣ ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានទៅក្នុងតម្លៃគម្រោង

ប្រភេទ៤ ចំណូលមូលធនផ្សេងៗ (មាត្រា៨ អនុក្រឹត្យ ២៦)។

ចំណូលរបស់ឃុំ សង្កាត់ត្រូវបានកំណត់ និងប្រមូលតាមបទប្បញ្ញត្តិដោយឡែក។ ចំណាយរបស់ឃុំ សង្កាត់ត្រូវបានសន្យា ជម្រះបញ្ជី ធ្វើអាណត្តិកិច្ច និងទូទាត់ដោយមានលិខិតយុត្តិការត្រឹមត្រូវ

ច្បាស់លាស់ តាមនីតិវិធី និងបទប្បញ្ញត្តិដូចមានចែងក្នុង ជំពូកទី២ ជំពូកទី៣ និងជំពូកទី៤នៃអនុក្រឹត្យនេះ។ ចំណាយប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធត្រូវរ៉ាប់រងដោយខ្ទង់ចំណូលដែលបានមកពីបន្ទុកអ្នកប្រើប្រាស់ និងចំណុចដែលទទួលបានពីមុខងារជាភ្នាក់ងារ (មាត្រា ១០ អនុក្រឹត្យ២៦)។

**២.១.២. ប្រភពចំណាយរបស់ឃុំ សង្កាត់**

ចំណាយចរន្តចែកជា ៧ ប្រភេទ៖

ប្រភេទ១ ចំណាយបៀវត្ស និងប្រាក់បំណាច់

ប្រភេទ២ ចំនាយរដ្ឋបាលទូទៅ

ប្រភេទ៣ ចំណាយសាធារណៈ

ប្រភេទ៤ ចំណាយសម្រាប់មុខងារជាភ្នាក់ងារ

ប្រភេទ៥ ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច

ប្រភេទ៦ ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច

ប្រភេទ៧ ចំណាយមិនបានគ្រោងទុក (មាត្រា ៥ អនុក្រឹត្យលេខ ២៦)។

ចំណាយមូលធនចែកចេញជា ២ ប្រភេទ៖

ប្រភេទ១ ចំណាយវិនិយោគផ្នែករដ្ឋបាល

ប្រភេទ២ ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន (មាត្រា ៧ អនុក្រឹត្យលេខ ២៦)។

ចំណាយទាំងឡាយខាងក្រោមនេះ ត្រូវបានចាត់ទុកជាចណាយចាំបាច់របស់ឃុំសង្កាត់ ដែលត្រូវឆ្លុះបញ្ចាំងជាអាទិភាពក្នុងថវិកា៖

១- ចំណាយបៀវត្ស និងប្រាក់បំណាច់

២- ចំណាយទុកដាក់ថែរក្សាឯកសារ

៣- ចំណាយលើថ្លៃឈ្នួលថែទាំទីស្នាក់ការឃុំ សង្កាត់

៤- ចំណាយថែទាំ និងប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធ ដែលឃុំសង្កាត់ទទួលខុសត្រូវ

៥- ចំណាយរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

៦- ចំណាយបន្តគម្រោងការវិនិយោគកំពុងដំណើរការ

៧- ចំណាយចាំបាច់ដទៃទៀតដែលស្របច្បាប់ ឬបទបញ្ញាដែលបានកំណត់ (មាត្រា ៩ អនុក្រឹត្យលេខ ២៦)។

### ២.១.៣. ប្រតិទិននៃការរៀបចំថវិកា

គម្រោងថវិកាត្រូវរៀបចំឡើង ក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពី គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ហើយបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគម្រោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃទី៣១ ខែតុលា។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិកាតាមផ្នែក និងតាមប្រភេទនីមួយៗ (មាត្រា១១)។

មេឃុំ ចៅសង្កាត់ ត្រូវធានាឲ្យមានការចូលរួមពីសាធារណៈជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកា តាមរយៈវិធានការទាំងឡាយដូចខាងក្រោមៈ

- គម្រោងថវិកាត្រូវតែផ្សាយជាសារណៈ យ៉ាងតិច ២សប្តាហ៍ មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការផែនការ និងថវិកា ត្រូវបើកចំហរដល់ សាធារណៈជនដែលចាប់អារម្មណ៍លើការត្រួតពិនិត្យលើគម្រោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសម្រេចលើគម្រោងថវិកា
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបង្កើតតយន្តការផ្សេងៗ ដើម្បីជម្រុយឲ្យមានការចូលរួមពីសាធារណៈជន លើកិច្ចការមូលដ្ឋាន (មាត្រា១២)។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនគម្រោងថវិកាដែលត្រូវបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងឲ្យបានមុនថ្ងៃទី៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់។

គម្រោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារដែលពាក់ព័ន្ធដូចខាងក្រោមៈ

- របាយការណៈសង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូល និងចំណាយ ព្រមទាំងកម្រិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណៈសង្ខេបស្តីពីការអនុវត្តថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេប នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ក្នុងការអភិវឌ្ឍឃុំ សង្កាត់ប្រសិនបើមាន
- កំណត់ហេតុ ស្តីពីកិច្ចប្រជុំ អនុម័តលើគម្រោងថវិកា
- កំណត់ហេតុ ស្តីពីកិច្ចប្រជុំ អនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា១៣)។

  អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាឲ្យបានមុនថ្ងៃទី៣០ ខែវិច្ឆិកា

ការត្រួតពិនិត្យអនុលោមភាព ត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោម:

១- ទម្រង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំថវិកា

២- តុល្យភាពថវិកា និងការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ

៣- លក្ខខណ្ឌនៃការប្រើប្រាស់ មូលនិធិឃុំ សង្កាត់ដែលទទួលបាន

៤- ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់

៥-តម្រូវការថវិកាវិនិយោគ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការ របស់ឃុំ សង្កាត់។

អភិបាលខេត្ត ក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជម្រើសនៃការចំណាយដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រៅពីពិនិត្យលើលក្ខខណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព (មាត្រា១៤)។

ប្រសិនបើ គម្រោងថវិកាត្រូវបានបំពេញតាមលក្ខខណ្ឌនៃការត្រួតពិនិត្យអនុលោមភាព ដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ត្រូវបញ្ជាក់លើគម្រោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនមេឃុំ ចៅសង្កាត់។ សេក្តីជូនដំណឹង ត្រូវភ្ជាប់ជាមួយឯកសារថវិកា ដែលមានហត្ថលេខាសង្ខេបរបស់ អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ។

អភិបាលខេត្ត ក្រុងត្រូវចម្លងជូនសេក្តីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង (មាត្រា១៥)។

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងបន្ទាន់ជាលាយលក្ខណ៍អក្សរដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់ពីមូលហេតុ ហើយណែនាំមេឃុំ ចៅសង្កាត់ឲ្យអនុវត្តន៍លើវិធានការកែតម្រូវ។

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យលើគម្រោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើតដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរង្វង់១៥ថ្ងៃ បន្ទាប់ពីបានទទួលសេក្តីជូនដំណឹងរបស់អភិបាលខេត្ត ក្រុង។

បន្ទាប់ពីពិភាក្សាមេឃុំ ចៅសង្កាត់ ខកខានមិនបានបញ្ជូនគម្រោងថវិកាកែតម្រូវជូនអភិបាលខេត្ត ក្រុងបញ្ជាក់ទទួលស្គាល់។

ប្រសិនបើមេឃុំ ចៅសង្កាត់ ខកខានមិនបានបញ្ជូនគម្រោងថវិកាដែលបានពិនិត្យឡើងវិញដល់ក្នុងរង្វង់មួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណោងខាងលើ ឬគម្រោងថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតបបានទៅនឹងការត្រួតពិនិត្យអនុលោមភាព ពេលនោះអភិបាលខេត្តមានសិទ្ធិចាត់វិធានការកែសម្រួលចាំបាច់ មុនពេលបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា។ អភិបាល

ខេត្ត ក្រុងត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនដល់មេឃុំ ចៅសង្កាត់ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង តាមនីតិវិធីដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ។

ក្នុងករណីមានការមិនចុះសម្រួលរវាងមេឃុំ ចៅសង្កាត់ ជាមួយអភិបាលខេត្ត ក្រុង មេឃុំ ចៅ សង្កាត់ ត្រូវបញ្ជូនករណីនេះ ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យសម្រេច។ សេចក្តីសម្រេច របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាត់ទុកជាការសម្រេចចុងក្រោយ (មាត្រា១៦)។

ក្នុងករណីអភិបាលខេត្ត ក្រុង មិនបានបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា មុនថ្ងៃទី០១ ខែ មករា នៃឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវបានអនុញ្ញាត្តិឲ្យអនុវត្តន៍ជាបណ្តោះអាសន្នលើចំណាយប្រចាំខែ ក្នុងកម្រិត ១/១២ នៃថវិកាដែលបានអនុម័តឆ្នាំមុន និងលើការប្រមូលចំណូលរបស់ឃុំ សង្កាត់តាម លក្ខខណ្ឌដែលបានអនុម័ត ដូចឆ្នាំមុនដែរ (មាត្រា១៧)។

**កថាខណ្ឌ ២ ការអនុម័តថវិកាឃុំ សង្កាត់**

ថវិកាឃុំ សង្កាត់អាចនឹងត្រូវបានកែតម្រូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែ ប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច ឬហិរញ្ញវត្ថុដែលជះឥទ្ធិពល ទៅលើព្យាករណ៍ដំបូងនៃចំណូល និង ចំណាយ (មាត្រា ១៨)។

ការកែតម្រូវថវិកាត្រូវរៀបចំ ពិនិត្យ អនុម័ត និងបញ្ជាក់ទទួលស្គាល់ តាមនីតិវិធីដូចមានចែង ក្នុងមាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ។

ប្រសិនបើ គោលបំណងនៃការកែតម្រូវថវិកា គ្រាន់តែជាការវិភាជន៍ធនធានឡើងវិញ ក្នុង ប្រភេទចំណាយតែមួយដោយមិនធ្វើឲ្យប្រែប្រួលចំនួនទឹកប្រាក់នៃប្រភេទចំណាយ ឬមិនធ្វើឲ្យប្រែ លប្រួលប្រភេទគម្រោង វិនិយោគនៅក្នុងថវិកា ដំបូងនោះ ពុំចាំបាច់សុំការបញ្ជាក់ទទួលស្គាល់ឡើង វិញពីអភិបាលខេត្ត ក្រុងទេ។ ក្នុងករណីនេះមេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងដល់អភិបាលខេត្ត ក្រុង មន្ទីរសេដ្ឋកិច្ច និងរញ្ញវត្ថុ និងរតនាគាំរខេត្ត ក្រុង អំពីការប្រែប្រួលធនធានវិភាជន៍ឡើងវិញមិនឲ្យ យឺតជាង ៥ថ្ងៃ បន្ទាប់ពីការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា១៩)។

ឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក មិនត្រូវលើស ៣% នៃថវិកាសរុប។ ខ្ទង់ ថវិកាចំណាយមិនបានគ្រោងទុកអាចត្រូវបានប្រើប្រាស់ សម្រាប់ធានាចំពោះចំណាយណាដែលការ វិភាជន៍មិនត្រូវបានកំណត់ជាក់លាក់នៅពេលឥណទានត្រូវបានអនុម័ត ឬសម្រាប់ឥណទានបំពេញ បន្ថែមជាគុណប្រយោជនជន៍ ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់ឃុំ សង្កាត់ (មាត្រា២០)។

មេឃុំ ចៅសង្កាត់ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សាឃុំ សង្កាត់មុនពេលសម្រេចចិត្តលើការ ប្រើប្រាស់ឥណទានថវិកាចំណាយមិនបានគ្រោងទុក។

នៅដំណាច់ឆ្នាំថវិកា គណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុងត្រូវរៀបចំបិទបញ្ជី និងធ្វើរបាយការណ៍។

គណនេយ្យករត្រូវធ្វើរបាយការណ៍បិទបញ្ជីជូនមេឃុំ ចៅសង្កាត់ដើម្បីផ្ទៀងផ្ទាត់គណនីថវិកា ជាមួយឃុំ សង្កាត់។ គណនេយ្យករ និងមេឃុំ ចៅសង្កាត់ត្រូវត្រួតពិនិត្យ កែតម្រូវ លេខ និងឯកភាព លើរបាយការណ៍បិទបញ្ជីនោះ។

របាយណ៍បិទបញ្ជីបង្ហាញនូវតួលេខអនុវត្តជាក់ស្តែង របស់ថវិកាព្រមទាំងទ្រព្យសម្បត្តិ និង ស្ថានភាពរតនៈវត្ថុដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ (មាត្រា២១)។

មេឃុំ ចៅសង្កាត់ត្រូវដាក់របាយណ៍បិទបញ្ជីជូនក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ អនុម័ត ក្នុងខែមីនានៃឆ្នាំបន្ទាប់។ បន្ទាប់ពីការពិភាក្សា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយបោះឆ្នោត លើសេចក្តីសម្រេច ស្តីពី ការបិទបញ្ជីថវិកា។

សេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិកាត្រូវៈ

១- បញ្ជាក់នូវចំណូល ចំណាយជាក់ស្តែងដែលសម្រេចបានក្នុងឆ្នាំថវិកា

២- លុបចោលឥណទានថវិកាដែលមិនបានប្រើប្រាស់

៣- អនុញ្ញាត្តិឲ្យផ្ទេរលទ្ធផលនៃឆ្នាំថវិកាទៅគណនី មូលនិធិបម្រុង

បន្ទាប់ពីបានការអនុម័តរួចយ៉ាងយូរ៧ថ្ងៃ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូន «សេចក្តី សម្រេចស្តីពីការបិទបញ្ជីថវិកា» ទៅអភិបាលខេត្ត ក្រុងដើម្បីពិនិត្យបញ្ជាក់ទទួលស្គាល់ដោយ ភ្ជាប់ជាមួយនូវៈ

- របាយការណ៍បិទបញ្ជីគណនេយ្យ
- របាយការណ៍ ស្តីពី សកម្មភាពទូទៅនៃឃុំ សង្កាត់
- កំណត់ហេតុនៃការពិភាក្សាអនុម័តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា ២២)។

មូលនិធិបម្រុង ត្រូវប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយមូលធននៃថវិកាឆ្នាំក្រោយ (មាត្រា២៣)។

### កថាខណ្ឌ ៣ ការគ្រប់គ្រងការចំណាយ

ចំណាយត្រូវសមស្របទៅនឹងថវិការបស់ឃុំ សង្កាត់ និងសមស្របតាមច្បាប់ និងបទបញ្ញា ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

ដំណើរការនៃការចំណាយរបស់ឃុំ សង្កាត់ រួមមានដំណើរការទាំងឡាយដូចខាងក្រោមៈ

១- ការសន្យា

២- កិច្ចជម្រះបញ្ជី

៣- អាណត្តិកិច្ច

៤- ការទូទាត់ (មាត្រា៣៩)។

ការសន្យាត្រូវមានកិច្ចសន្យា ឬការព្រមព្រៀងក្នុងការទិញមានលក្ខណៈបន្ទាន់ ឬការផ្គត់ផ្គង់សម្ភារៈ និងសេវាកម្មនៅពេលខាងមុខ។ ការសន្យាគឺជាការបញ្ជាក់នូវកាតព្វកិច្ចរបស់ឃុំ សង្កាត់ដែលត្រូវទូទាត់ ប្រសិនបើអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការបានបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។

មុនសន្យាលើចំណាយណាមួយ មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- ចំណាយណាដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា

២- មាននៅក្នុងឥណទានថវិកាព្រមទាំងមូលនិធិទំនេរគ្រប់គ្រាន់ និងត្រឹមត្រូវតាមមាតិកាថវិកា

៣- នីតិវិធិលទ្ធកម្មអនុវត្តបានត្រឹមត្រូវ

៤- ការសន្យាចំណាយត្រូវបានកត់ត្រាដូចដែលបានបញ្ជាក់ក្នុងមាត្រា៣៣ នៃអនុក្រឹត្យនេះ

ការសន្យាចំណាយមិនត្រូវស្ថិតជាកម្មវត្ថុនៃការត្រួតពិនិត្យជាមុនរបស់មន្ត្រីត្រួតពិនិត្យហរិញ្ញវត្ថុ និងអាជ្ញាធរខេត្តក្រុងទេ (មាត្រា ៤០)។

ក្នុងកិច្ចជម្រះបញ្ជី មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- សម្ភារៈទាំងឡាយត្រូវបានប្រគល់ ឬសេវាត្រូវបានផ្តល់ដូចដែលបានបញ្ជាក់ត្រឹមត្រូវតាមកិច្ចសន្យា ឬការបញ្ជាទិញដែលបានព្រមព្រៀង

២- វិក័យប័ត្រដែលដាក់ជូនឲ្យអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ត្រូវតែត្រឹមត្រូវទៅនឹងចំនួន និងការងារអនុវត្តន៍បាន (មាត្រា ៤១)។

បន្ទាប់ពីកិច្ចជម្រះបញ្ជីមេឃុំ ចៅសង្កាត់ត្រូវចេញអណត្តិបើកប្រាក់។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនអាណត្តិបើកប្រាក់រួមជាមួយឯកសារពាក់ព័ន្ធឲ្យគណនេយ្យឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ហើយទន្ទឹមនឹងនេះ ជូនដំណឹងដល់អ្នកទទួលប្រាក់។

ក្នុងករណី ចំនួនទឹកប្រាក់ចំណាយស្ថិតនៅក្នុងកម្រិតកំណត់ ដែលបានអនុញ្ញាត្តិឲ្យប្រើប្រាស់បេឡាបុរប្រទានការទូទាត់ត្រូវអនុវត្តតាមនីតិវិធីចំណាយនៃបេឡាបុរប្រទានរបស់ឃុំ សង្កាត់ (មាត្រា ៤២)។

គណនេយ្យករត្រូវធ្វើការទូទាត់ដល់អ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ ឬក៏អ្នកទទួលសិទ្ធិដែលបានបញ្ជាក់ក្នុងអាណត្តិបើកប្រាក់។

មុនពេលទូទាត់ គណនេយ្យត្រូវធ្វើការត្រួតពិនិត្យ និងបញ្ជាក់លើចំណុចដូចខាងក្រោម:

១-អាណត្តិបើកប្រាក់ត្រូវបានចុះហត្ថលេខាដោយអាណាប័កដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ

២- មន្ត្រីមុខការបានបញ្ជាក់ថា សម្ភារៈត្រូវបានទទួល ឬសេវាត្រូវបានផ្តល់ត្រឹមត្រូវតាមការព្រមព្រៀង

៣- វិក័យប័ត្រ និងឯកសារទាំងឡាយដែលជាសំណូមពរនៃការទូទាត់ពិតជាត្រឹមត្រូវ

៤- ឥណទានយកពិតជាត្រឹមត្រូវតាមកិច្ចសន្យា

៥- សំណើទូទាត់ពិតជាត្រឹមត្រូវតាមប្រភេទចំណាយ ព្រមទាំងមានថវិកាទំនេរគ្រប់គ្រាន់ក្នុងប្រភេទ ចំណាយនេះ

៦- ស្ថានភាពគណនីប្រាក់បញ្ញើឃុំ សង្កាត់មានលទ្ធភាពទូទាត់បាន

៧- ការទូទាត់ត្រូវមានលក្ខណៈជាការរំដោះបំណុល។

ក្នុងករណីមិនបានបំពេញលក្ខខណ្ឌខាងលើគ្រប់គ្រាន់ គណនេយ្យករមានសិទ្ធិផ្អាកការទូទាត់ ហើយជូនដំណឹងជាបន្ទាន់ដល់មេឃុំ សង្កាត់ដោយបញ្ជាក់អំពីមូលហេតុ និងសំណូមពរបំពេញបន្ថែម (មាត្រា ៩៣)។

ក្នុងករណីមានបញ្ហាក្នុងការទូទាត់ឃុំ ចៅសង្កាត់ និងគណនេយ្យករត្រូវពិភាក្សាដើម្បីរកដំណោះស្រាយស្របតាមនីតិវិធីនៃការទូទាត់។

ប្រសិនបើការពិភាក្សាមិនបានឯកភាពគ្នាទេ ឃុំ ចៅសង្កាត់ត្រូវបញ្ជូនសំណុំរឿងនេះទៅអភិបាលខេត្ត ក្រុងជំនួយដោះស្រាយ។ សេចក្តីសម្រេចរបស់អភិបាលខេត្ត ក្រុងចាត់ទុកជាការសម្រេចចុងក្រោយចំពោះទំនាស់នេះ និងត្រូវភ្ជាប់ជាឯកសារបន្ថែមនៃការទូទាត់ (មាត្រា៩៤)។

## ផ្នែក ២ ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់សម្រាប់ឃុំ សង្កាត់

ប្រព័ន្ធគណនេយ្យឃុំ សង្កាត់ត្រូវបម្រើដល់គោលបំណងទាំងឡាយដូចខាងក្រោមៈ

១- បញ្ជីការរាល់ការប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

២- ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាក់ស្តែងឲ្យទាន់ពេលវេលា ដែលអាចជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

៣- ផ្តល់មូលដ្ឋានសម្រាប់តាមដានអនុវត្តថវិការបស់ឃុំ សង្កាត់

គណនេយ្យឃុំ សង្កាត់រួមមានៈ

ក) គណនេយ្យហិរញ្ញវត្ថុៈ គណនា ចុះបញ្ជី និងធ្វើរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុ របស់ឃុំ សង្កាត់។

ខ) គណនេយ្យថវិកាៈ តាមដាន និងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍ថវិកាដែលបានអនុម័ត (មាត្រា ២៤)។

គណនេយ្យហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ គឺផ្អែកលើមូលដ្ឋានសាច់ប្រាក់ និងតាមវិធីបញ្ជីការទ្វេភាគ។ មាតិកាគណនេយ្យត្រូវស្របគ្នាជាមួយមាតិកាថវិការបស់ឃុំ សង្កាត់។

ឃុំ សង្កាត់ណាដែលមានធនធានហិរញ្ញវត្ថុ ឬសមត្ថភាពគ្រប់គ្រាន់មានកម្រិតខ្សោយអាចប្រើប្រាស់មាតិកាគណនេយ្យ និងមានមាតិកាថវិកាដែលមានលក្ខណៈសាមញ្ញ (មាត្រា ២៥)។

រតនាគារខេត្ត ក្រុងត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់ និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោមះ

១- ប្រមូល ឬទទួលចំណូលរបស់ឃុំ សង្កាត់

២- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយមេឃុំ ចៅសង្កាត់

៣- គ្រប់គ្រង និងបើកផ្តល់ថវិកាឃុំ សង្កាត់

៤- បញ្ជីប្រតិបត្តិការហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា២៥ នៃអនុក្រឹត្យនេះ

៥- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់

៦- ថែរក្សាទុកដាក់រាល់ឯកសារសក្ខីប័ត្រ និងបញ្ជីគណនេយ្យរបស់ឃុំ សង្កាត់ (មាត្រា២៦)។

មេឃុំ ចៅសង្កាត់ជាអាណាប័ក មានសិទ្ធិអំណាចប្រមូលចំណូល សន្យាចំណាយ និងបញ្ជាចំណាយ ដោយផ្អែកលើថវិកាឃុំ សង្កាត់ដែលបានអនុម័ត។

មេឃុំ ចៅសង្កាត់អាចផ្ទេរជាលាយលក្ខណ៍អក្សរ ក្នុងការសម្រេចលើថវិកាទៅឲ្យ ជំទប់ ចៅសង្កាត់រង ណាមួយរបស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់។

អាណាប័ក និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គម្រូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ (មាត្រា ២៧)។

សិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឲ្យមនុស្សតែម្នាក់ លើកលែងតែករណីទាំងឡាយដូចមានចែងក្នុងមាត្រា៣១ នៃអនុក្រឹត្យនេះ (មាត្រា ២៨)។

ឃុំ សង្កាត់នីមួយៗ ត្រូវបើកគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង។ គណនីនេះត្រូវបានប្រើប្រាស់សម្រាប់ទទួលចំណូល និងទូទាត់ចំណាយ (មាត្រា ២៩)។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអនុញ្ញាត្តិដល់ឃុំ សង្កាត់ក្នុងការគ្រប់គ្រងទាំងស្រុង ឬមួយចំណែកនៃប្រតិបត្តិការសាច់ប្រាក់តាមរយៈគណនីបើកនៅធនាគារពាណិជ្ជប្រតិស្រុកណាមួយ (មាត្រា៣០)។

ឃុំ សង្កាត់ ត្រូវធ្វើការទូទាត់ដល់ចំណាយទាំងឡាយណាដែលមានចំនួនទឹកប្រាក់នៅក្រោមកម្រិតមួយជាកំណត់តាមនីតិវិធីបេឡាបុរេប្រទាន។

មេឃុំ ចៅសង្កាត់ ត្រូវតែងតាំងមន្ត្រីមួយរូបរបស់រដ្ឋបាលឃុំ សង្កាត់ឲ្យទទួលខុសត្រូវក្នុងការគ្រប់គ្រងបេឡាបុរេប្រទាននេះ។

បេឡាករបុរេប្រទានត្រូវទទួលខុសត្រូវលើសុវត្ថិភាពរបស់មូលនិធិ ព្រមទាំងឯកសារ សក្ខីប័ត្រពាក់ព័ន្ធ និងកត់ត្រារាល់ប្រតិបត្តិការ។ បេឡាករបុរេប្រទានបំពេញភារកិច្ច ក្រោមការត្រួតពិនិត្យរួមគ្នារបស់មេឃុំ ចៅសង្កាត់ និងគណនេយ្យឃុំ សង្កាត់ (មាត្រា៣១)។

ការទទួលខុសត្រូវក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធអាចនឹងប្រគល់ឲ្យមន្ត្រីម្នាក់របស់រដ្ឋបាលឃុំ សង្កាត់ ធ្វើជាម្នាក់ងារប្រមូលចំណូល។

ភ្នាក់ងារប្រមូលចំណូលត្រូវបានតែងតាំងឡើង និងបំពេញភារកិច្ចមានលក្ខណៈដូចគ្នា នឹងបេឡាករបុរេប្រទានដែរ (មាត្រា ៣២)។

មេឃុំ ចៅសង្កាត់ត្រូវធានាថាប្រព័ន្ធគណនេយ្យថវិកាត្រូវបានអនុវត្ត។

ប្រព័ន្ធគណនេយ្យថវិកាត្រូវបញ្ជីកា ការសន្យាចំណាយ និងការអនុញ្ញាតឲ្យចំណាយដោយមេឃុំ ចៅសង្កាត់សម្រាប់គោលបំណងនៃការតាមដានកិច្ចប្រតិបត្តិការថវិកា (មាត្រា ៣៣)។

## ផ្នែក ៣ សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់

ឃុំ ចៅសង្កាត់ត្រូវធានាថាយន្តការត្រួតពិនត្យផ្ទៃក្នុងប្រព័ន្ធគ្រប់គ្រង ត្រូវបានអនុវត្តដើម្បីសម្រេចឲ្យបានតាមគោលដៅដូចខាងក្រោម:

- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តព្រមទាំងស្របតាមច្បាប់ និងបទបញ្ញាជាធរមាន
- ធនធានត្រូវបានទុកដាក់ម៉ត់ចត់ មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហារិញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និងលាតត្រដាងក្នុងរបាយការណ៍ (មាត្រា៥៥)។

របាយការណ៍ហារិញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ជាកម្មវត្ថុសម្រាប់សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច។

គោលបំណងនៃសវនកម្ម គឺសំដៅធានាភាពជាក់លាក់ ត្រឹមត្រូវនៃពតិមានហារិញ្ញវត្ថុ វាយតម្លៃការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធី។ របាយការណ៍សវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយជាសារធារណៈ (មាត្រា៥៦)។

គណនី និងប្រតិបត្តិការឃុំ សង្កាត់អាចត្រូវធ្វើសវនកម្មដោយស្ថាប័នជាតិ ឬដោយសវនកម្មឯករាជ្យមិនមែនរដ្ឋាភិបាលតាមសំណូមពររបស់ម្ចាស់ជំនួយក្រៅប្រទេស ដែលផ្តល់ហិរញ្ញប្បទានដល់ឃុំ សង្កាត់ (មាត្រា៥៧)។

អភិបាលខេត្ត ក្រុងត្រូវធានាថាសវនកម្មដែលមានលក្ខណៈជាការពិគ្រោះយោបល់ ធ្វើឡើងតាមរូបភាព ជាជំនួយបច្ចេកទេស និងមានលក្ខណៈជាការកសាងសមត្ថភាពខាងការគ្រប់គ្រង ហិរញ្ញវត្ថុ និងប្រតិបត្តិការ ត្រូវបានផ្តល់ឲ្យដល់ឃុំ សង្កាត់ទៀងទាត់ជាប្រចាំ(មាត្រា៥៨)។

ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការពិនិត្យ តាមដានការអនុវត្តន៍របស់ក្រុមប្រឹក្សា នឹងរដ្ឋបាលឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវធានាថាៈ

១- រាល់ពត៌មានស្តីពីសកម្មភាព និងគណនីរបស់ឃុំ សង្កាត់ត្រូវបានផ្សាយជាសាធារណៈ

២- ការទទួលមតិសាធារណៈ និងការពិគ្រោះយោបល់ត្រូវបានប្រព្រឹត្តនៅក្នុងដំណើរការរៀបចំថវិកា

៣- ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និងអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា៥៩)។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ ទៅលើប្រធានបទមួយស្តីអំពី**ទំនើបកម្មរដ្ឋបាលឃុំ សង្កាត់នៅកម្ពុជា ចាប់ពីឆ្នាំ២០០១ រហូតដល់បច្ចុប្បន្ន** យើងទទួលបានលទ្ធផលជាច្រើនពីការធ្វើកំណែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋគ្រប់រូបឲ្យសមស្របទៅនឹងសេចក្តីត្រូវការដែលមានលក្ខណៈយ៉ាងឆាប់រហ័សទាន់ចិត្ត និងមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តជាក់ស្តែង។

បើទោះបីជាការធ្វើកំណែទ្រង់នេះ មិនទទួលបានភាពរលូនទាំងស្រុងក៏ដោយ យ៉ាងណាមិញ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក៏បានខិតខំប្រឹងប្រែងដើម្បីរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍនៃការផ្តល់សេវានៅឃុំ សង្កាត់។ ទំនើបកម្មនៃរដ្ឋបាលឃុំ សង្កាត់ គឺមានន័យថាការធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការរៀបចំ និងការប្រព្រឹត្តទៅនៃដំណើរការក្នុងសកម្មភាពបម្រើវិស័យសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែងការធ្វើទំនើបកម្មនេះ គឺនៅមានកម្រិតនៅឡើយទេ។ ក្នុងការអនុវត្តការធ្វើកំណែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវ ក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៨ កម្មវិធិជាតិរយៈពេល ១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ និងផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣) នៃកម្មវិធីជាតិ នាថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០១០។ លើសពីនេះទៅទៀតរាជរដ្ឋាភិបាលក៏បានដាក់ចេញផងដែរ នូវលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនានាសម្រាប់ការគ្រប់គ្រង និងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើទំនើបកម្មគឺក្នុងគោលបំណង ជួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករបស់ខ្លួន ឲ្យក្លាយជារដ្ឋបាលមួយដែលមានសមត្ថភាពបំពេញការងារទៅតាមអាណត្តិ និងតួនាទី ភារកិច្ចប្រកបដោយប្រសិទ្ធិភាព។ ជាក់ស្តែងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ គឺផ្តោតសំខាន់ទៅចំណុចពីរធំៗតែប៉ុណ្ណោះ ទី១ គឺទំនើបកម្មនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងទី២ គឺទំនើបកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។ ពួកយើងបានដកស្រង់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីដាក់បញ្ចូល**ក្នុងអត្ថបទឲ្យកាន់តែច្បាស់អំពីការគ្រប់គ្រប់នៅរដ្ឋបាលឃុំ សង្កាត់។**

ដើម្បីពង្រឹងការផ្តល់សេវានេះឲ្យកាន់តែមានភាពល្អប្រសើរជាងមុន ក្រសួងមហាផ្ទៃបានធ្វើការផ្លាស់ប្តូរបរិបទនៃដំណើរការការងារ និងបានរៀបចំនូវផែនការក្នុងការចាត់តាំងនៅតួនាទីភារកិច្ចនៅឃុំ សង្កាត់។ ក្រសួងមហាផ្ទៃក៏បានដាក់ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងសណ្តាប់ធ្នាប់នៅក្នុងភូមិ ឃុំ សង្កាត់របស់ខ្លួនឲ្យកាន់តែមានសុខសន្តិភាព គ្មានក្មេងទំនើង គ្មានសកម្មភាពឆក់ ប្លន់ លួចគ្រប់ប្រភេទ គ្មានការរំខានពីសម្លេងធុងបាស គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីភេទ និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។ល។

ទំនើបកម្មនៃរដ្ឋបាលមានគោលដៅច្រើនក្នុងការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាល និងប្រសិទ្ធភាពនៃសកម្មភាពរដ្ឋបាល និងគុណភាពនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ។

ដូចនេះទំនើបកម្មនៃរដ្ឋបាលឃុំ សង្កាត់នៅកម្ពុជាចាប់ពីឆ្នាំ២០០១ រហូតមកដល់បច្ចុប្បន្ន គឺបានបង្ហាញឲ្យយើងឃើញពីការផ្លាស់ប្តូរនៅក្នុងការគ្រប់គ្រង ក៏ដូចជាការដឹកនាំដែលប្រកបទៅដោយចីរភាព និងភាពរីកចម្រើនរុងរឿង។

# អនុសាសន៍

## អនុសាសន៍

ដើម្បីឆ្លើយតបទៅនឹងការធ្វើទំនើបកម្មឃុំ សង្កាត់នៅព្រះរាជាណាចក្រកម្ពុជា និងធានាឲ្យទំនើបកម្មនេះមានលក្ខណៈជាក់ស្តែងនៅក្នុងឃុំ សង្កាត់គេត្រូវ៖

- គោលរពគោលការណ៍អភិបាលកិច្ចល្អ
- ធ្វើឲ្យកាន់តែប្រសើរឡើង តាវកាលិកនៃសេវារដ្ឋបាលថ្នាក់ឃុំ សង្កាត់ ដោយប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គោរពនីតិរដ្ឋ ផ្ទេរអំណាចឲ្យបានជាក់លាក់
- ធ្វើកំណែទម្រង់ហិញ្ញវត្ថុឃុំ សង្កាត់ ដោយផ្តល់ទៅឲ្យឃុំ សង្កាត់នៃហរិញ្ញវត្ថុធំដុំ
- បង្កើតអង្គភាពទទួលពាក្យបណ្តឹងតាមពត៌មានវិទ្យា
- វិក្រឹត្យភាពសាកសិទ្ធិភាពនៃឃុំ សង្កាត់
- បណ្តុះបណ្តាលធនធានមនុស្ស
- បង្កើតបញ្ជូលរួម៖ ដំណោះស្រាយមួយដើម្បីទុកទទួលប្រជាពលរដ្ឋឲ្យបានល្អប្រសើរ
- ភ្នាក់ងារទទួលនីមួយម្នាក់មានឯកទេសរបស់ខ្លួន និងវិស័យសមត្ថកិច្ចរបស់ខ្លួន ដើម្បីផ្តល់ពត៌មានឲ្យប្រជាពលរដ្ឋនៅកម្រិតទីមួយ ទោះជាតម្រូវការប្រភេទណាក៏ដោយ មុននឹងតម្រង់ទិសឡើងវិញឆ្ពោះទៅសេវាឯកទេស ប្រសិនបើចាំបាច់។ គោលបំណងនៃដំណើរការសម្រាអ្នកប្រើប្រាស់៖ ទទួលបាននូវការទទួលជាលក្ខណៈបុគ្គលហើយប្រមូលផ្តុំ យកពត៌មានរហូតដល់ការចុះឈ្មោះ និង/ឬធ្វើការទទាត់។ ផលប្រយោជន៍មានយ៉ាងច្បាស់លាស់៖ សេវានេះមានលក្ខណៈងាយស្រួលហើយឆាប់រហ័ស អាចឲ្យសាមីខ្លួនបានចម្លើយទៅនឹងសំណួររបស់ខ្លួន ឬត្រូវនិយាយទៅកាន់អ្នកណាឲ្យបានពិតប្រាកដ សម្រាប់ពត៌មានចាំបាច់ ដោយពុំចាំបាច់ជួបមនុស្សច្រើន។ល។
- បង្កើតប្រព័ន្ធឌីជីថល (Digital) គឺបង្កើតនយោបាយប្រកបដោយចីរភាពនៅក្នុងសេវារបស់ខ្លួន និងកំណត់អំពីការប្រើប្រាស់ក្រដាស់ដោយធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋលែងត្រូវការផ្លាស់ប្តូរទីតាំងទៅឃុំ សង្កាត់ ឬពន្លឿននៃការងារនៃសេវាថែមទៀតតាមរយៈការដាក់ក្នុងប្រព័ន្ធ និងចូលប្រើប្រាស់ឯកសារដោយគ្រាន់តែចុចរកឯកសារឃុំ សង្កាត់នៅក្នុងប្រព័ន្ធអ៊ីនធើណេត គឺជាដំណោះស្រាយជាអាទិភាពដើម្បីសម្រេចគោលដៅទាំងនេះ។ ការដាក់ឯកសាររដ្ឋបាលក្នុងប្រព័ន្ធឌីជីថល (Digital)អាចធ្វើទំនើបកម្មបានយ៉ាងឆាប់រហ័ស ទោះជារឿងនេះអាចតំណាងឲ្យការប្រឈមមួយមិនអាចធ្វេសប្រហែសបានឡើយ។

# ឯកសារពិគ្រោះ

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្នែករដ្ឋបាល

- ច្បាប់ស្តីពី **ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់**
- អនុក្រឹត្យលេខ១៦ស្តីពី **មូលនិធិឃុំ-សង្កាត់** ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ២០០២
- អនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពី **បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ**
- ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពី **ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**
- អនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពី **បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ**
- ប្រកាសអន្តរក្រសួងស្តីពីការកែប្រែកម្រសេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ**
- ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្នែកហិរញ្ញវត្ថុ

- ព្រះរាជក្រម នស/រកម/០៦១១/០១១ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ព្រះរាជក្រម នសហិរញ្ញ ស្តីពីប្រើ ច្បាប់ឱ្យប្រកាសស្តីពី ការ១២០៩/០២៦ រកម//២០១០គ្រប់គ្រង ឆ្នាំ ការសម្រាប់វត្ថុ
- ប្រកាសលេខ ៤៨២ សហវថ្ងៃប្រក ចុះ.ទី ២០ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការដាក់អនុវត្តចំណាយប្រតិបត្តិការអាទិភាពសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- សារាចរណែនាំលេខ ០៨ សរណន ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ។
- សារាចរលេខ ០០៤ សហវ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការណែនាំលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

- សេចក្តីថ្លែងហេតុរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៣៧សជណ.កបច ចុះថ្ងៃទី . ការសម្រាប់ហិរញ្ញវត្ថុស្តីពីច្បាប់ព្រាងសេចក្តីនៃ ២០១២ខែ តុលា ឆ្នាំ ២៦ ២០១៣ឆ្នាំ គ្រប់គ្រង ។
- សេចក្តីជូនដំណឹង លេខ ០០៣ សហវ ២០១៣ខែ មករា ឆ្នាំ ២៤ថ្ងៃទី ចុះ ហម. អនុវត្តការស្តីពីចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ។
- កំណត់បង្ហាញ លេខ ០០៤ សហវ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១២ នៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ។
- ព្រះរាជក្រម នសព្រះបរមសម្តេចព្រះបាទព្រះករុណារបស់ ១២១២/០១០រកម// នាថ នរោត្តម សីហមុនី ប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ។
- សារាចរណែនាំលេខ ០០៨ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៣ ។
- សារាចរណែនាំលេខ ០០៧ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ។
- អនុក្រឹត្យលេខ ៤២៦ អនក្រស្តីពីការ ២០១៣ខែ មិថុនា ឆ្នាំ ១៩បក ចុះថ្ងៃទី . ថវិកាអង្គភាពអនុវត្តដាក់ឱ្យនិង រៀបចំ ។
- សេចក្តីថ្លែងហេតុលេខ ២៨ សជណ២០១៣ខែតុលា ឆ្នាំ ៣១ថ្ងៃទីច ចុះកប. នៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤
- ព្រះរាជក្រមលេខ នស ២០១៣ខែវិច្ឆិកា ឆ្នាំ ២៨ថ្ងៃទីចុះ១១១៣/០១៥ រកម// ២០១៤ឆ្នាំ ការគ្រប់គ្រងសម្រាប់ហិរញ្ញវត្ថុច្បាប់ ស្តីពីឱ្យប្រើប្រកាសដែល
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- ព្រះរាជក្រម នសប្រកាសដែល ២០១៤ខែធ្នូ ឆ្នាំ ១៨ថ្ងៃទីចុះ១២១៤/០២៦ រកម// ២០១៥ឆ្នាំ ការគ្រប់គ្រងសម្រាប់ហិរញ្ញវត្ថុច្បាប់ ស្តីពីឱ្យប្រើ

- កំណត់បង្ហាញលេខ ០០២ សហវ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ នៃសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥
- សេចក្ដីថ្លែងហេតុលេខ ៥២នៃ ២០១៤ខែតុលា ឆ្នាំ ២៥ថ្ងៃទីច ចុះណ.កបសជ. ២០១៥ឆ្នាំ ការគ្រប់គ្រងសម្រាប់វញ្ញវត្ថុហិស្ដីពីសេចក្ដីព្រាងច្បាប់
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- អនុក្រឹត្យលេខ២៦ អនក្រ. បក **ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់**
- ប្រកាស **កំណែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ប្រព័ន្ធលទ្ធកម្មសាធារណៈ និងគៀរគរចំណូលជាតិ "សហវក"**
- ចំណូលចំណាយថវិកាថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៩
- ប្រកាសអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- ក្របខណ្ឌនៃការរៀបចំច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បទឧទ្ទេសនាមរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឱកាសពិភាក្សាសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- ព្រះរាជក្រម នសព្រះបរមនាថ នរោត្តម សីហាសម្ដេចព្រះបាទរបស់ព្រះករុណា០៥១១/០០៩ រកម// ឲ្យមុនី ប្រកាសប្រើច្បាប់ ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។
- ព្រះរាជក្រម នស របស់ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម១២០៨/០២០ រកម//សីហាមុនី ប្រកាសឱ្យប្រើ ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩

## គេហទំព័រ

- www.ncdd.gov.kh
- http://www.Fonctionpublique.gouv.sn

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| តារាងឧបសម្ព័ន្ធ | | | |
|---|---|---|---|
| ល.រ | កម្មវត្ថុ | ទំព័រ | ផ្សេងៗ |
| 1 | ច្បាប់ស្ដីពី **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** | | |
| 2 | អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ខែមេសាឆ្នាំ ២០០២ ស្ដីពី **ប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់** | | |
| 3 | អនុក្រឹត្យ លេខ២៦៤ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលាឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | | |
| 4 | តារាងចំនួនឃុំ សង្កាត់ ក្រុង ស្រុក រាជធានី ខេត្ត និង សមាជិកក្រុមប្រឹក្សាសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ | | |
| 5 | តម្លៃសេវារដ្ឋបាលថ្នាក់ក្រោមជាតិ នៅសង្កាត់ផ្សារដើមថ្កូវ | | |
| 6 | | | |
| 7 | | | |
| 8 | | | |
| 9 | | | |
| 10 | | | |

# ឧបសម្ព័ន្ធ១

# ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភះ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :៚.

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវរៀប.

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

**មាត្រា ១៦.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៕

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។/.

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងជីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។ ៙

## ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម ៖

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប ៖

- ជំទប់ទី ១ មួយរូប
- ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប ៖

- ចៅសង្កាត់រងទី ១ មួយរូប
- ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំតាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។៚

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

មាត្រា ៣៦.-

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យ-ខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

មាត្រា ៣៧.-

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យ-ខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងចាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

មាត្រា ៣៨.-

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម/

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។

- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

មាត្រា ៤៣.-

ក្នុងតួនាទីបំពេញកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសម្ព័ន្ធភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ល.។.

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសិរុះសិរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។ល។

**មាត្រា ៤៩.-**

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យ ពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទេ ឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- វាយតំលៃប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចបំបែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។/.

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ៥៨.-**

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៩.-**

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

**មាត្រា ៦០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦១.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

**មាត្រា ៦២.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ស.ភ.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៚

**មាត្រា ៦៤.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ។ល។

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្ងៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។

មាត្រា ៧៤.-

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

មាត្រា ៧៥.-

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដីជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧៦.-

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យ។បានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវរៀបចំឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន : ៩.т.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**វិន័យរួមមាន :**

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើ អាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។ល។

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិវរកមគោលនយោបាយសំរាប់ផ្តល់ព័ត៌មាននិងតំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល.។.

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខ : ៦០ ច.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ២០០៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ឧបសម្ព័ន្ធ២

# អនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំសង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
  យោងសារតីអង្គប្រជុំលើកទី១៣ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី១៣ ១៤ ខែមីនា ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមមាត្រា៧៣ មាត្រា៧៥ មាត្រា៨១ មាត្រា៨២ និង មាត្រា៨៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ២.-**

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវបានបង្កើតឡើងដែលរួមមានបទប្បញ្ញត្តិ និងនីតិវិធីទាក់ទងទៅនឹងការងារដូចខាងក្រោម:

១/ ថវិកាឃុំ សង្កាត់

២/ ប្រពន្ធ័គណនេយ្យនិងប្រព័ន្ធទូទាត់សំរាប់ឃុំ សង្កាត់

៣/ ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់

៤/ ទ្រព្យសម្បត្តិឃុំ សង្កាត់

៥/ សវនកម្ម និង របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ។

## ជំពូកទី ២

## ថវិកាឃុំ សង្កាត់

## ផ្នែកទី ១

## ចំណូល ចំណាយរបស់ឃុំ សង្កាត់

**មាត្រា ៣.-**

ថវិកាឃុំ សង្កាត់ ជាលិខិតគតិយុត្តិដែលគ្រោង និង អនុញ្ញាតចំណូល និង ចំណាយដោយផ្អែកលើមូលដ្ឋានឆ្នាំ ។

ឆ្នាំថវិការបស់ឃុំ សង្កាត់ ចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា និង បញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ។

ថវិកាឃុំ សង្កាត់ត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់ឃុំ សង្កាត់ដោយមិនគិតដល់ប្រភពដើម ឬ ចរិតលក្ខណៈឡើយ ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់។

**មាត្រា ៤.-**

ថវិកាឃុំ សង្កាត់ត្រូវបានរៀបចំឡើងជាពីរផ្នែក:

- ផ្នែកទី១: ចំណូល និង ចំណាយចរន្ត

– ផ្នែកទី២: ចំណូល និង ចំណាយមូលធន ។

ចំណូលសរុបត្រូវតុល្យភាពនឹងចំណាយសរុប ។ អតិរេកក្នុងផ្នែកទី១ ត្រូវបានប្រើប្រាស់ជាគុណប្រយោជន៍ក្នុងផ្នែកទី២ ។

ចំណូលមូលធនមិនត្រូវបានប្រើប្រាស់សំរាប់ធ្វើហិរញ្ញប្បទានដល់ចំណាយចរន្ត លើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក ។

**មាត្រា ៥.–**

ចំណាយចរន្តចែកចេញជា ៧ប្រភេទ :

ប្រភេទ១– ចំណាយបៀវត្ស និង ប្រាក់បំណាច់

ប្រភេទ២– ចំណាយរដ្ឋបាលទូទៅ

ប្រភេទ៣– ចំណាយសេវាសាធារណៈ

ប្រភេទ៤– ចំណាយសំរាប់មុខងារជាភ្នាក់ងារ

ប្រភេទ៥– ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច

ប្រភេទ៦– ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច

ប្រភេទ៧– ចំណាយមិនបានគ្រោងទុក

**មាត្រា ៦.–**

ចំណូលចរន្តចែកចេញជា ៥ប្រភេទ :

ប្រភេទ១– ចំណូលពន្ធមូលដ្ឋាន

ប្រភេទ២– ចំណូលមិនមែនសារពើពន្ធ

ប្រភេទ៣– ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់រដ្ឋបាលទូទៅ

ប្រភេទ៤– ចំណូលពីការអនុវត្តនីមុខងារជាភ្នាក់ងារ

ប្រភេទ៥– ចំណូលចរន្តផ្សេងៗ ។

**មាត្រា ៧.–**

ចំណាយមូលធនចែកចេញជា ២ប្រភេទ :

ប្រភេទ១– ចំណាយវិនិយោគផ្នែករដ្ឋបាល

ប្រភេទ២– ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ។

**មាត្រា ៨.–**

ចំណូលមូលធនចែកចេញជា ៤ប្រភេទ :

ប្រភេទ១- ចំណូលម៉ូលនិធិបំរុងដូចមានចែងក្នុងមាត្រា ២២នៃអនុក្រឹត្យនេះ

ប្រភេទ២- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន

ប្រភេទ៣- ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានទៅក្នុងគំរោងគំរោង

ប្រភេទ៤- ចំណូលមូលធនផ្សេងៗ ។

មាត្រា ៩.-

ចំណាយទាំងឡាយខាងក្រោមនេះ ត្រូវបានចាត់ទុកជាចំណាយចាំបាច់ របស់ឃុំ សង្កាត់ ដែលត្រូវឆ្លុះបញ្ចាំងជាអាទិភាពក្នុងថវិកា :

១- ចំណាយបៀវត្ស និង ប្រាក់បំណាច់

២- ចំណាយទុកដាក់ថែរក្សាឯកសារ

៣- ចំណាយលើថ្លៃឈ្នួលថែទាំទីស្នាក់ការឃុំ សង្កាត់

៤- ចំណាយថែទាំ និង ប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធ ដែលឃុំ សង្កាត់ទទួលខុសត្រូវ

៥- ចំណាយរៀបចំផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់

៦- ចំណាយបន្តគំរោងការវិនិយោគកំពុងដំណើរការ

៧- ចំណាយចាំបាច់ដទៃទៀតដែលស្របតាមច្បាប់ ឬបទបញ្ញាដែលបានកំណត់ ។

មាត្រា ១០.-

ចំណូលរបស់ឃុំ សង្កាត់ត្រូវបានកំណត់ និងប្រមូល តាមបទប្បញ្ញត្តិដោយឡែក ។

ចំណាយរបស់ឃុំ សង្កាត់ត្រូវបានសន្យា ជំរះបញ្ជី ធ្វើអាណត្តិកិច្ច និង ទូទាត់ ដោយមានលិខិតយុត្តិការត្រឹមត្រូវច្បាស់លាស់ តាមនិតិវិធី និងបទប្បញ្ញត្តិ ដូចមានចែងក្នុង ជំពូកទី២ ជំពូកទី៣ និង ជំពូកទី៤ នៃអនុក្រឹត្យនេះ ។

ចំណាយប្រតិបត្តិការ និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធ ត្រូវរ៉ាប់រងដោយខ្ទង់ចំណូលដែលបានមកពីបន្ទុកអ្នកប្រើប្រាស់ និង ចំណូលដែលទទួលបានពីមុខងារជាភ្នាក់ងារ ។

## ផ្នែកទី ២
## ការរៀបចំ និង ការអនុម័តថវិកា

មាត្រា ១១.-

គំរោងថវិកាត្រូវរៀបចំឡើង ក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យនិង អនុម័ត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកានាកិច្ចប្រជុំសាធារណៈអោយបានមុន ថ្ងៃទី៣១ ខែតុលា ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកាតាមផ្នែកនិងតាមប្រភេទនិមួយៗ ។

**មាត្រា ១២.-**

មេឃុំ ចៅសង្កាត់ត្រូវធានាអោយមានការចូលរួមពីសាធារណជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកា តាមរយៈវិធានការទាំងឡាយដូចខាងក្រោម:

- គំរោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈ យ៉ាងតិច២សប្តាហ៍ មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបើកចំហដល់ សាធារណជនដែលចាប់អារម្មណ៍លើការពិនិត្យគំរោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសំរេចលើគំរោងថវិកា ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតនូវយន្តការផ្សេងៗ ដើម្បីជំរុញអោយមានការចូលរួមពីសាធារណជន លើកិច្ចការមូលដ្ឋាន ។

**មាត្រា ១៣.-**

មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនគំរោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងអោយបានមុនថ្ងៃ ទី៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់ ។

គំរោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម:

- របាយការណ៍សង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូល និង ចំណាយ ព្រមទាំងកំរិតចូលរួម របស់ ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេប នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ប្រសិនបើមាន
- កំណត់ហេតុ ស្តីពី កិច្ចប្រជុំ អនុម័តលើគំរោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៤.-**

អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគំរោងថវិកាអោយបានមុនថ្ងៃទី៣០ ខែវិច្ឆិកា ។

ការត្រួតពិនិត្យអនុលោមភាពត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោម:

១-ទំរង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំថវិកា

២-តុល្យភាពថវិកា និង ការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះ

៣-ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលទទួលបាន

៤-ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់

៥-តំរូវការថវិកាវិនិយោគ សំរាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការ របស់ឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជំរើសនៃការចំណាយដែលបានសំរេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្រៅពីពិនិត្យលើល័ក្ខខ័ណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព ។

## មាត្រា ១៥.-

ប្រសិនបើ គំរោងថវិកាត្រូវបានបំពេញតាមល័ក្ខខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាព ដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ត្រូវបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ជូនមេឃុំ ចៅសង្កាត់ ។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកា ដែលមានហត្ថលេខាសង្ខេបរបស់ អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ ។

អភិបាលខេត្ត ក្រុងត្រូវចំលងជូនសេចក្តីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង ។

## មាត្រា ១៦.-

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងបន្ទាន់ ជាលាយល័ក្ខអក្សរដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់ពីមូលហេតុហើយណែនាំដល់មេឃុំ ចៅសង្កាត់អោយអនុវត្តវិធានការ កែតម្រូវ ។

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យកែសំរួលគំរោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូន ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរយះ១៥ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាល ខេត្ត ក្រុង ។

បន្ទាប់ពីការពិភាក្សា មេឃុំ ចៅសង្កាត់ ផ្ញើគំរោងថវិកាកែតម្រូវជូនអភិបាលខេត្ត ក្រុង បញ្ជាក់ទទួលស្គាល់ ។

ប្រសិនបើ មេឃុំ ចៅសង្កាត់ ខកខានមិនបានបញ្ជូនគំរោងថវិកាដែលបានពិនិត្យឡើងវិញដល់អភិបាល ខេត្ត ក្រុង ក្នុងរយះមួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងខាងលើ ឬ គំរោងថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតប បានទៅនឹងការត្រួតពិនិត្យអនុលោមភាព ពេលនោះអភិបាលខេត្ត ក្រុង មានសិទ្ធិចាត់វិធានការកែសំរួលចាំបាច់ មុនពេល បញ្ជាក់ទទួលស្គាល់លើគំរោងថវិកា ។អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួនដល់មេឃុំ ចៅសង្កាត់ មន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង តាមនីតិវិធីដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ក្នុងករណីមានការមិនចុះសំរុងគ្នារវាងមេឃុំ ចៅសង្កាត់ ជាមួយអភិបាលខេត្ត ក្រុង មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូន ករណីនេះ ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យសំរេច ។ សេចក្តីសំរេច របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាត់ទុកជាការសំរេច ចុងក្រោយ ។

**មាត្រា ១៧.-**

ក្នុងករណី អភិបាលខេត្ត ក្រុង មិនបានបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា មុនថ្ងៃទី០១ ខែមករានៃឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវបានអនុញ្ញាតអោយអនុវត្តជាបណ្តោះអាសន្នលើចំណាយប្រចាំខែក្នុងកំរិត ១/១២ នៃថវិកាដែលបានអនុម័ត ឆ្នាំមុន និងលើការប្រមូលចំណូលរបស់ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដែលបានអនុម័ត ដូចឆ្នាំមុនដែរ ។

## ផ្នែកទី ៣
## ការអនុវត្តន៍ថវិកា

**មាត្រា ១៨.-**

ថវិកាឃុំ សង្កាត់ អាចនឹងត្រូវបានកែតំរូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃ ល័ក្ខខ័ណ្ឌសេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុ ដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ ។

**មាត្រា ១៩.-**

ការកែតំរូវថវិកាត្រូវរៀបចំ ពិនិត្យ អនុម័ត និងបញ្ជាក់ទទួលស្គាល់ តាមនីតិវិធីដូចមានចែងក្នុងមាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ប្រសិនបើ គោលបំណងនៃការកែតំរូវថវិកា គ្រាន់តែជាការវិភាជន៍ធនធានឡើងវិញ ក្នុងប្រភេទចំណាយតែមួយ ដោយមិនធ្វើអោយប្រែប្រួលចំនួនទឹកប្រាក់នៃប្រភេទចំណាយ ឬមិនធ្វើអោយប្រែប្រួលប្រភេទគំរោងវិនិយោគនៅក្នុងថវិកាដំបូងនោះ ពុំចាំបាច់សុំការបញ្ជាក់ទទួលស្គាល់ឡើងវិញពីអភិបាលខេត្ត ក្រុងទេ។ ក្នុងករណីនេះ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងដល់អភិបាល ខេត្ត ក្រុង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត ក្រុង អំពីការប្រែប្រួលធនធានវិភាជន៍ឡើងវិញមិនអោយយឺតជាង៥ថ្ងៃ បន្ទាប់ពីការពិភាក្សាសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២០.-**

ឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក មិនត្រូវលើស ៣% នៃថវិកាសរុប ។ ខ្ទង់ថវិកានៃចំណាយមិនបានគ្រោងទុកអាចត្រូវបានប្រើប្រាស់ សំរាប់ធានាចំពោះចំណាយទាំងឡាយណាដែលការវិភាជន៍មិនត្រូវបានកំណត់ជាក់លាក់នៅពេលឥណទានត្រូវបានអនុម័ត ឬសំរាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់ឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សាឃុំ សង្កាត់មុនពេលសំរេចចិត្តលើការប្រើប្រាស់ឥណទានថវិកាចំណាយមិនបានគ្រោងទុក ។

**មាត្រា ២១.-**

នៅដំណាច់ឆ្នាំថវិកា គណនេយ្យករឃុំ សង្កាត់នៅរតនាគារខេត្ត ក្រុងត្រូវរៀបចំបិទបញ្ជី និងធ្វើ

គណនេយ្យករត្រូវធ្វើរបាយការណ៍បិទបញ្ជីជូនមេឃុំ ចៅសង្កាត់ដើម្បីផ្ទៀងផ្ទាត់គណនីថវិកា ជាមួយឃុំ សង្កាត់ ។ គណនេយ្យករ និងមេឃុំ ចៅសង្កាត់ ត្រូវពិនិត្យ កែតំរូវលេខនា និង ឯកភាពលើរបាយការណ៍បិទបញ្ជីនោះ ។

របាយការណ៍បិទបញ្ជីបង្ហាញនូវតួលេខអនុវត្តជាក់ស្តែង របស់ថវិកាព្រមទាំងទ្រព្យសម្បត្តិ និង ស្ថានភាពគនៈវត្ថុ ដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ ។

**មាត្រា ២២.-**

មេឃុំ ចៅសង្កាត់ត្រូវដាក់របាយការណ៍បិទបញ្ជីជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ អនុម័ត ក្នុងខែមីនានៃឆ្នាំបន្ទាប់។ បន្ទាប់ពីការពិភាក្សា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយបោះឆ្នោត លើសេចក្តីសំរេច ស្តីពីការបិទបញ្ជីថវិកា ។

សេចក្តីសំរេចស្តីពីការបិទបញ្ជីថវិកាត្រូវ:

១- បញ្ជាក់នូវចំណូល ចំណាយជាក់ស្តែងដែលសំរេចបានក្នុងឆ្នាំថវិកា

២- លុបចោលឥណទានថវិកាដែលមិនបានប្រើប្រាស់

៣- អនុញ្ញាតអោយផ្ទេរលទ្ធផលនៃឆ្នាំថវិកាទៅគណនី មូលនិធិបំរុង ។

បន្ទាប់ពីបានអនុម័តរួចយ៉ាងយូរ៧ថ្ងៃ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូន "សេចក្តីសំរេចស្តីពីការបិទបញ្ជីថវិកា" ទៅអភិបាលខេត្ត ក្រុង ដើម្បីពិនិត្យបញ្ជាក់ទទួលស្គាល់ដោយភ្ជាប់ជាមួយនូវ:

- របាយការណ៍បិទបញ្ជីគណនេយ្យ
- របាយការណ៍ ស្តីពី សកម្មភាពទូទៅនៃឃុំ សង្កាត់
- កំណត់ហេតុនៃការពិភាក្សាអនុម័តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ២៣.-**

មូលនិធិបំរុងត្រូវប្រើប្រាស់សំរាប់ហិរញ្ញប្បទានដល់ចំណាយមូលធននៃថវិកាឆ្នាំក្រោយ។

## ជំពូកទី ៣

## ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធទូទាត់សំរាប់ឃុំ សង្កាត់

**មាត្រា ២៤.-**

ប្រព័ន្ធគណនេយ្យឃុំ សង្កាត់ត្រូវបំរើដល់គោលបំណងទាំងឡាយដូចខាងក្រោម:

១- បញ្ជីការាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

២- ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាក់ស្តែងអោយទាន់ពេលវេលា ដែលអាចជាកម្មវត្ថុសំរាប់ ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

៣- ផ្តល់មូលដ្ឋានសំរាប់តាមដានការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ។

គណនេយ្យឃុំ សង្កាត់ រួមមាន:

ក ៖ គណនេយ្យហិរញ្ញវត្ថុ : គណនា ចុះបញ្ជី និងធ្វើរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុ របស់ឃុំ សង្កាត់ ។

ខ ៖ គណនេយ្យថវិកា : តាមដាន និងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍ថវិកាដែលបានអនុម័ត ។

**មាត្រា ២៥.-**

គណនេយ្យហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ គឺផ្អែកលើមូលដ្ឋានសាច់ប្រាក់ និងតាមវិធីបញ្ជីកាទ្វេភាគ ។ មាតិកាគណនី ត្រូវស្របគ្នាជាមួយមាតិកាថវិការបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ណាដែលមានធនធានហិរញ្ញវត្ថុ ឬ សមត្ថភាពគ្រប់គ្រងមានកំរិតខ្សោយអាចប្រើប្រាស់មាតិកាគណនី និងមាតិកាថវិកាដែលមានលក្ខណៈសាមញ្ញ ។

**មាត្រា ២៦.-**

រតនាគារខេត្ត ក្រុងត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម :

១- ប្រមូល ឬ ទទួលចំណូលរបស់ឃុំ សង្កាត់

២- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយមេឃុំ ចៅសង្កាត់

៣- គ្រប់គ្រង និង បើកផ្តល់ថវិកាឃុំ សង្កាត់

៤- បញ្ជីកាប្រតិបត្តិការហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា២៥ នៃអនុក្រឹត្យនេះ

៥- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់

៦- ថែរក្សាទុកដាក់រាល់ឯកសារសក្ខីប័ត្រ និង បញ្ជីគណនេយ្យរបស់ឃុំ សង្កាត់ ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់ជាអាណាប័ក មានសិទ្ធិសំរេចអោយប្រមូលចំណូល សន្យាចំណាយ និង បញ្ជាចំណាយ ដោយផ្អែក លើថវិកាឃុំ សង្កាត់ដែលបានអនុម័ត ។

មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរ ក្នុងការសំរេចលើថវិកាទៅអោយ ជំទប់ ចៅសង្កាត់រង ណាមួយ របស់រដ្ឋបាលឃុំ សង្កាត់ ។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងត្រួត ពិនិត្យរបស់មេឃុំ ចៅសង្កាត់ ។

អាណាប័ក និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ ។

**មាត្រា ២៨.-**

សិទ្ធិបញ្ជាចំណាយ និង ការទូទាត់មិនត្រូវប្រគល់អោយមនុស្សតែម្នាក់ លើកលែងតែករណីទាំងឡាយដូចមានចែង ក្នុងមាត្រា ៣១នៃអនុក្រឹត្យនេះ ។

មាត្រា ២៩.-

ឃុំ សង្កាត់នីមួយៗត្រូវបើកគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង ។ គណនីនេះត្រូវបានប្រើប្រាស់សំរាប់ទទួលចំណូល និងទូទាត់ចំណាយ ។

មាត្រា ៣០.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចអនុញ្ញាតដល់ឃុំ សង្កាត់ក្នុងការគ្រប់គ្រងទាំងស្រុង ឬមួយចំណែកនៃប្រតិបត្តិការសាច់ប្រាក់តាមរយៈគណនីបើកនៅធនាគារពាណិជ្ជប្រតិស្រុតណាមួយ ។

មាត្រា ៣១.-

ឃុំ សង្កាត់ត្រូវធ្វើការទូទាត់ដល់ចំណាយទាំងឡាយដែលមានចំនួនទឹកប្រាក់នៅក្រោមកំរិតមួយជាកំណត់ តាមនីតិវិធីបេឡាបុរេប្រទាន ។

មេឃុំ ចៅសង្កាត់ត្រូវតែងតាំងមន្ត្រីមួយរូបរបស់រដ្ឋបាលឃុំ សង្កាត់អោយទទួលខុសត្រូវក្នុងការគ្រប់គ្រងបេឡាបុរេប្រទាននេះ ។

បេឡាករបុរេប្រទានត្រូវទទួលខុសត្រូវលើសុវត្ថិភាពរបស់មូលនិធិ ព្រមទាំងឯកសារ សក្ខីប័ត្រពាក់ព័ន្ធ និង កត់ត្រារាល់ប្រតិបត្តិការ ។ បេឡាករបុរេប្រទានបំពេញភារកិច្ច ក្រោមការត្រួតពិនិត្យរួមគ្នា របស់មេឃុំ ចៅសង្កាត់ និងគណនេយ្យករឃុំ សង្កាត់ ។

មាត្រា ៣២.-

ការទទួលខុសត្រូវក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធអាចនឹងប្រគល់អោយមន្ត្រីម្នាក់ របស់រដ្ឋបាល ឃុំ សង្កាត់ ធ្វើជាភ្នាក់ងារប្រមូលចំណូល ។

ភ្នាក់ងារប្រមូលចំណូលត្រូវបានតែងតាំងឡើង និង បំពេញភារៈកិច្ចមានលក្ខណៈដូចគ្នា នឹងបេឡាករបុរេប្រទានដែរ ។

មាត្រា ៣៣.-

មេឃុំ ចៅសង្កាត់ត្រូវធានាថាប្រព័ន្ធគណនេយ្យថវិកាត្រូវបានអនុវត្ត ។

ប្រព័ន្ធគណនេយ្យថវិកាត្រូវបញ្ជីកា ការសន្យាចំណាយ និង ការអនុញ្ញាតអោយចំណាយដោយមេឃុំ ចៅសង្កាត់ សំរាប់គោលបំណងនៃការតាមដានកិច្ចប្រតិបត្តិការថវិកា។

## ជំពូកទី ៤

## ឯាយការណ៍ហិរញ្ញវត្ថុ

**មាត្រា ៣៤.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវបំរើនូវគោលបំណងដូចខាងក្រោម:

១- តាមដានកិច្ចប្រតិបត្តិការចំណូលនិងចំណាយរបស់ឃុំ សង្កាត់ ដោយប្រៀបធៀបជាមួយនឹងការព្យាករណ៍ថវិកា

២- វាយតំលៃស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ ដោយផ្តល់នូវពត៌មានអំពីប្រភព និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

៣- បង្កលក្ខណៈដល់មេឃុំ ចៅសង្កាត់ក្នុងការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់លើ

៤- ឆ្លុះបញ្ចាំងអោយឃើញថាកិច្ចប្រតិបត្តិការឆ្លើយតបបានទៅនឹងថវិកាដែលបានអនុម័តនិងបទប្បញ្ញត្តិ គតិយុត្តិផ្សេងទៀត ។

**មាត្រា ៣៥.-**

ឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍ដូចខាងក្រោម:

១- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកាប្រចាំខែ : របាយការណ៍នេះត្រូវមានទំរង់ជារបាយការណ៍ចំណូល ចំណាយផ្អែកតាមមាតិកាថវិកា ។ ត្រូវប្រៀបធៀបការអនុវត្តន៍ជាក់ស្តែងទៅនឹងការព្យាករណ៍ថវិកា និងបង្ហាញអំពីស្ថានភាពរតនៈវត្ថុរបស់ឃុំ សង្កាត់

២- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកាប្រចាំឆមាស ដែលមានទំរង់ដូចគ្នាទៅនឹងរបាយការណ៍ប្រចាំខែ ដែរ

៣- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួមមាន:

- របាយការណ៍ស្តីពីចំណូល ចំណាយប្រចាំឆ្នាំ
- ការផ្ទៀងផ្ទាត់គណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នៅរតនាគារ
- របាយការណ៍ស្តីពីអចលនវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវមានភាពជាក់ស្តែងនិងប្រាកដប្រជា ទាក់ទងទៅ នឹងល័ក្ខខ័ណ្ឌទាំងឡាយ នៃការអនុវត្តន៍ថវិកាព្រមទាំងស្ថានភាពហិរញ្ញវត្ថុដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ ។

**មាត្រា ៣៦.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវភ្ជាប់ជាមួយនូវរបាយការណ៍លំអិត ស្តីពីសកម្មភាពរបស់ឃុំ សង្កាត់ ។ របាយការណ៍សកម្មភាពប្រចាំឆ្នាំត្រូវពិពណ៌នា និងវាយតំលៃ:

- ការអនុវត្តន៍ការងាររបស់ឃុំ សង្កាត់ ក្នុងការប្រមូលចំណូល និងចំណាយ
- សមិទ្ធិផលរបស់ឃុំ សង្កាត់ក្នុងការផ្តល់សេវាសាធារណៈ ប្រៀបធៀបជាមួយនឹងទិសដៅ ផែនការ
- ស្ថានភាពសេដ្ឋកិច្ចរបស់ឃុំ សង្កាត់ និងផលប៉ះពាល់ពីប្រតិបត្តិការរបស់ឃុំ សង្កាត់ លើសុខមាលភាពរបស់ប្រជាជន ។

របាយការណ៍សកម្មភាព ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ ។

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាព ជាឯកសារជំនួយក្នុងការបិទបញ្ជីគណនីឃុំ សង្កាត់ តាមការកំណត់ ។

**មាត្រា ៣៧.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំឡើងដោយគណនេយ្យកររបស់ឃុំ សង្កាត់ និងត្រូវផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍គណនេយ្យថវិកា ដែលគ្រប់គ្រងដោយរដ្ឋបាលឃុំ សង្កាត់ ស្របទៅតាមប្រតិទិន ដូចខាងក្រោម:

- អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់សំរាប់របាយការណ៍ប្រចាំខែ
- អោយបានមុនថ្ងៃទី ២១ ខែកក្កដា សំរាប់របាយការណ៍ឆមាស
- អោយបានមុនថ្ងៃទី ៣១ ខែមករា នៃឆ្នាំបន្ទាប់សំរាប់របាយការណ៍ប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

មេឃុំ ចៅសង្កាត់ត្រូវពិនិត្យនិងឯកភាពទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយគណនេយ្យករ និងត្រូវផ្ញើជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិភាក្សា និងអនុម័តទាន់ពេលវេលា ដោយភ្ជាប់នូវរបាយការណ៍លំអិតអំពីសកម្មភាព ។

ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានពិភាក្សា អនុម័តរួចមេឃុំ ចៅសង្កាត់ត្រូវ:

១- ផ្ញើរបាយការណ៍ជូនអភិបាលខេត្ត ក្រុង និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២- ផ្សព្វផ្សាយជាសាធារណៈ ។

## ជំពូកទី ៥
## ការគ្រប់គ្រងចំណាយ
### ផ្នែកទី ១
### ខួបនៃការចំណាយ

**មាត្រា ៣៩.-**

ចំណាយត្រូវសមស្របទៅនឹងថវិការបស់ឃុំ សង្កាត់និងសមស្របតាមច្បាប់ និង បទបញ្ញាទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ដំណើរការនៃចំណាយរបស់ឃុំ សង្កាត់ រួមមានដំណាក់កាលទាំងឡាយដូចខាងក្រោម:

១- ការសន្យា

២- កិច្ចជំរះបញ្ជី

៣- អាណត្តិកិច្ច

៤- ការទូទាត់ ។

**មាត្រា ៤០.-**

ការសន្យាត្រូវមានកិច្ចសន្យាឬការព្រមព្រៀងក្នុងការទិញមានលក្ខណៈបន្ទាន់ ឬ ការផ្គត់ផ្គង់សំភារៈ និងសេវាកម្មនៅពេលខាងមុខ ។ ការសន្យាគឺជាការបញ្ជាក់នូវកាតព្វកិច្ចរបស់ឃុំ សង្កាត់ដែលត្រូវទូទាត់ ប្រសិនបើ អ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការបានបំពេញគ្រប់លក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

មុនពេលសន្យាលើចំណាយណាមួយ មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- ចំណាយដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា

២- មាននៅក្នុងឥណទានថវិកាព្រមទាំងមានមូលនិធិទំនេរគ្រប់គ្រាន់ និង ត្រឹមត្រូវតាមមាតិកាថវិកា

៣- នីតិវិធីលទ្ធកម្មនឹងអនុវត្តបានត្រឹមត្រូវ

៤- ការសន្យាចំណាយត្រូវបានកត់ត្រាដូចដែលបានបញ្ជាក់ក្នុងមាត្រា ៣៣នៃអនុក្រឹត្យនេះ

ការសន្យាចំណាយមិនត្រូវស្ថិតជាកម្មវត្ថុនៃការត្រួតពិនិត្យជាមុនរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង អាជ្ញាធរខេត្ត ក្រុងទេ។

**មាត្រា ៤១.-**

ក្នុងកិច្ចជំរះបញ្ជី មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- សំភារៈទាំងឡាយត្រូវបានប្រគល់ ឬសេវាត្រូវបានផ្តល់ដូចដែលបានបញ្ជាក់ត្រឹមត្រូវតាមកិច្ចសន្យា ឬការបញ្ជាទិញដែលបានព្រមព្រៀង

២- វិក័យប័ត្រដែលដាក់ជូនដោយអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ត្រូវតែត្រឹមត្រូវទៅនឹងចំនួន និង ការងារអនុវត្តបាន។

**មាត្រា ៤២.-**

បន្ទាប់ពីបញ្ចប់កិច្ចជំរះបញ្ជី មេឃុំ ចៅសង្កាត់ត្រូវចេញអាណត្តិបើកប្រាក់ ។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនអាណត្តិបើកប្រាក់រួមជាមួយឯកសារពាក់ព័ន្ធអោយគណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ហើយទន្ទឹមនឹងនេះ ជូនដំណឹងដល់អ្នកត្រូវទទួលប្រាក់ ។

ក្នុងករណី ចំនួនទឹកប្រាក់ចំណាយស្ថិតនៅក្នុងកំរិតកំណត់ ដែលបានអនុញ្ញាតអោយប្រើប្រាស់បេឡាបុរេប្រទានការទូទាត់ត្រូវអនុវត្តតាមនីតិវិធីចំណាយនៃបេឡាបុរេប្រទានរបស់ឃុំ សង្កាត់។

**មាត្រា ៤៣.-**

គណនេយ្យករត្រូវធ្វើការទូទាត់ដល់អ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ ឬក៏អ្នកទទួលសិទ្ធិដែលបានបញ្ជាក់ក្នុងអាណត្តិបើកប្រាក់។

មុនពេលទូទាត់ គណនេយ្យករត្រូវធ្វើការត្រួតពិនិត្យ និងបញ្ជាក់លើចំណុចដូចខាងក្រោម:

១- អាណត្តិបើកប្រាក់ត្រូវបានចុះហត្ថលេខាដោយអាណាប័កដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ

២- មន្ត្រីមុខការបានបញ្ជាក់ថា សំភារៈត្រូវបានទទួល ឬសេវាត្រូវបានផ្តល់ត្រឹមត្រូវតាមការព្រមព្រៀង

៣- វិក័យប័ត្រ និងឯកសារទាំងឡាយដែលជាសំណូមពរនៃការទូទាត់ពិតជាត្រឹមត្រូវ

៤- ឥណទាយកពិតជាត្រឹមត្រូវតាមកិច្ចសន្យា

៥- សំណើទូទាត់ពិតជាត្រឹមត្រូវតាមប្រភេទចំណាយ ព្រមទាំងមានថវិកាទំនេរគ្រប់គ្រាន់ក្នុងប្រភេទ ចំណាយនេះ

៦- ស្ថានភាពគណនីប្រាក់បញ្ញើឃុំ សង្កាត់ មានលទ្ធភាពទូទាត់បាន

៧- ការទូទាត់ត្រូវមានលក្ខណៈជាការរំដោះបំណុល ។

ក្នុងករណីមិនបានបំពេញល័ក្ខខ័ណ្ឌខាងលើគ្រប់គ្រាន់ គណនេយ្យករមានសិទ្ធិផ្អាកការទូទាត់ ហើយជូនដំណឹងជាបន្ទាន់ដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់អំពីមូលហេតុ និង សំណូមពរបំពេញបន្ថែម ។

## មាត្រា ៤៤.-

ក្នុងករណីមានបញ្ហាក្នុងការទូទាត់ មេឃុំ ចៅសង្កាត់ និង គណនេយ្យករត្រូវពិភាក្សាដើម្បីរកដំណោះស្រាយស្រប តាមនីតិវិធីនៃការទូទាត់ ។

ប្រសិនបើការពិភាក្សាមិនបានឯកភាពគ្នាទេ មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនសំណុំរឿងនេះទៅអភិបាលខេត្ត ក្រុងជួយដោះស្រាយ ។ សេចក្តីសំរេចរបស់អភិបាលខេត្ត ក្រុងចាត់ទុកជាការសំរេចចុងក្រោយចំពោះទំនាស់នេះ និងត្រូវភ្ជាប់ជាឯកសារបន្ថែមនៃការទូទាត់ ។

## ផ្នែកទី២

## ការទិញលទ្ធកម្មសាធារណៈ

## មាត្រា ៤៥.-

លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និង ការផ្តល់សេវាត្រូវតែស្របទៅតាមគោលការណ៍ទូទៅដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ។

## មាត្រា ៤៦.-

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការលទ្ធកម្មមួយទទួលបន្ទុកការងារទាំងឡាយរួមមាន:

១ -ធ្វើការវាយតំលៃលើការដេញថ្លៃរបស់អ្នកម៉ៅការ និង អ្នកផ្គត់ផ្គង់

២-ផ្តល់អនុសាសន៍ លើការសំរេចចុះកិច្ចសន្យា ។

គណៈកម្មការលទ្ធកម្មត្រូវធានាថា:

- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និងការផ្តល់សេវា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព និង សន្សំសំចៃ

- អ្នកម៉ៅការ និង អ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នាក្នុងការចូលរួមប្រកួតប្រជែងផ្គត់ផ្គង់សំភារៈ និងផ្តល់សេវាក្រោមល័ក្ខខ័ណ្ឌតែមួយ
- លទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ

**មាត្រា ៤៧.-**

គណៈកម្មការលទ្ធកម្មត្រូវមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - មេឃុំ ចៅសង្កាត់ ឬ អ្នកទទួលសិទ្ធិ | ប្រធាន |
| - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពីររូប | សមាជិក |
| - ស្មៀនឃុំ សង្កាត់ | លេខាធិការ |

ប្រធានគណៈកម្មការលទ្ធកម្មអាចអញ្ជើញបុគ្គលមួយចំនួនចូលរួមជាអ្នកជំនួយការ ឬជាអ្នកសង្កេតការណ៍។ ក្នុងការប្រជុំពិភាក្សាការងារ របស់ គណៈកម្មការលទ្ធកម្ម អ្នកជំនួយការ លេខាធិការ និងអ្នកសង្កេតការណ៍ ពុំមានសិទ្ធិសំរេចទេ។ គណៈកម្មការលទ្ធកម្ម ត្រូវធ្វើសេចក្តីសំរេចដោយសំលេងភាគច្រើន ។

ក្នុងករណីមានសំលេងស្មើគ្នានោះ សំលេងរបស់ប្រធានចាត់ទុកជាសំលេងឧត្តមភាព ។

**មាត្រា ៤៨.-**

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំ របស់គណៈកម្មការលទ្ធកម្ម មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសំរេចចុងក្រោយស្តីពីការប្រគល់កិច្ចសន្យា។

## ជំពូកទី ៦
## ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់រួមមានបីប្រភេទៈ

១-ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរសិទ្ធិអោយកាន់កាប់

២-ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯង

៣-ទ្រព្យសម្បត្តិដែលបានមកពីអំណោយនានា។

**មាត្រា ៥០.-**

ឃុំ សង្កាត់ត្រូវរក្សាការកត់ត្រាដោយឡែកប្រភេទទ្រព្យសម្បត្តិទាំងបីខាងលើ តាមប្រភេទនីមួយៗ នូវព័ត៌មានដូចខាងក្រោមៈ

១- លេខរៀង ឬលេខកូដ

២- យថាប្រភេទ

៣- កាលបរិច្ឆេទផ្ទេរសិទ្ធិអោយកាន់កាប់

៤- បរិមាណ និង តំលៃ

៥- ទីតាំងដែលទ្រព្យសម្បត្តិនោះទុកដាក់ ឬប្រើប្រាស់

មេឃុំ ចៅសង្កាត់ត្រូវធានាកត់ត្រាក្នុងបញ្ជីទ្រព្យសម្បត្តិអោយបានត្រឹមត្រូវ ។

**មាត្រា ៥១.-**

ចលនៈវត្ថុនានាត្រូវមានលេខកូដសំគាល់ដើម្បីងាយស្រួលដឹងថានៅទីកន្លែងណា និង អាចជួយដល់ការ កត់ត្រាបញ្ជីចលនៈវត្ថុ ។

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការមួយធ្វើសារពើភណ្ឌ អោយបានយ៉ាងតិច១ដងក្នុង១ឆ្នាំ ចំពោះអចលនៈវត្ថុរបស់ខ្លួន ដើម្បីដឹងបានចំនួនបាត់បង់ ហើយធ្វើការកែតម្រូវបញ្ជី ព្រមទាំងវាយតំលៃចំពោះស្ថានភាពរបស់ទ្រព្យសម្បត្តិ ដើម្បីរៀប ចំជួសជុល ថែទាំ ឬជំនួសថ្មី ។

លទ្ធផលនៃសារពើភ័ណ្ឌ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយបញ្ជីអចលនៈវត្ថុ បើឃើញមានការខុសគ្នា ត្រូវតែធ្វើការអង្កេតបញ្ជាក់មូលហេតុច្បាស់លាស់ និងកែតម្រូវបញ្ជី អចលនៈវត្ថុទៅតាមនោះ ។

តារាងសង្ខេប ព្រមទាំងរបាយការណ៍សារពើភ័ណ្ឌអចលនៈវត្ថុ ចាំបាច់ត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។

**មាត្រា ៥២.-**

អនុលោមតាមមាត្រា៨១ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលប្រគល់អោយ ដោយគ្មានការយល់ព្រមជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ ឯកភាពរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ ។

**មាត្រា ៥៣.-**

ឃុំ សង្កាត់មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែល[illegible]ដោយធនធានផ្ទាល់របស់ខ្លួន ។

ការលក់ដូរ ឬ ការផ្ទេរកម្មសិទ្ធិ ឬការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម[illegible]

១- មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការចំពោះកិច្ចមួយ ដើម្បី[illegible]ទ្រព្យសម្បត្តិ ។ គណៈកម្មការនេះត្រូវដឹកនាំដោយមេឃុំ ចៅសង្កាត់ និង[illegible]ទៀតជា គណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ។ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើ[illegible]

២- ដំណើរការលក់ដូរ ឬផ្ទេរត្រូវធានាអោយមានតម្លាភាព និង[illegible]ត្រូវគេ

៣-ក្នុងការលក់ដូរ ឬផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរេចផ្អែកតាម[illegible]ចំពោះកិច្ច

៤- ចំនួនទឹកប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិត្រូវរក្សាទុកក្នុងគណនីរបស់ឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ។

**មាត្រា ៥៤.-**

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ដែលបានមកពី អំណោយត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយនិងឃុំ សង្កាត់ ។

ក្នុងករណីអំណោយគ្មានល័ក្ខខ័ណ្ឌពីម្ចាស់អំណោយ ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៥៣នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៧
## សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់

**មាត្រា ៥៥.-**

មេឃុំ ចៅសង្កាត់ត្រូវធានាថាយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលមានក្នុងប្រព័ន្ធគ្រប់គ្រង ត្រូវបានអនុវត្តដើម្បីសំរេចអោយបានតាមគោលដៅដូចខាងក្រោម:

- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តព្រមទាំងស្របតាម ច្បាប់ និង បទបញ្ជាជាធរមាន
- ធនធានត្រូវបានទុកដាក់គត់មត់ មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហិរញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និង លាតត្រដាងក្នុងរបាយការណ៍ ។

**មាត្រា ៥៦.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ជាកម្មវត្ថុសំរាប់សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។

គោលបំណងនៃសវនកម្មគឺសំដៅធានាភាពជាក់លាក់ ត្រឹមត្រូវនៃពត៌មានហិរញ្ញវត្ថុ វាយតំលៃការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រង និង នីតិវិធី ។ របាយការណ៍សវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥៧.-**

គណនី និង ប្រតិបត្តិការរបស់ឃុំ សង្កាត់អាចត្រូវធ្វើសវនកម្មដោយស្ថាប័នជាតិ ឬដោយសវនករឯករាជ្យមិនមែនរដ្ឋាភិបាល តាមសំណូមពររបស់ម្ចាស់ជំនួយក្រៅប្រទេស ដែលផ្តល់ហិរញ្ញប្បទានដល់ឃុំ សង្កាត់ ។

**មាត្រា ៥៨.-**

អភិបាលខេត្ត ក្រុងត្រូវធានាថាសវនកម្មដែលមានលក្ខណៈជាការពិគ្រោះយោបល់ ធ្វើឡើងអោយស្មើភាព ក្នុងជំនួយបច្ចេកទេស និងមានលក្ខណៈជាការកសាងសមត្ថភាពខាងការគ្រប់គ្រង ហិរញ្ញវត្ថុ និង កិច្ចប្រតិបត្តិការ ត្រូវបានផ្តល់អោយឃុំ

ដល់ឃុំ សង្កាត់ទៀងទាត់ជាប្រចាំ ។

**មាត្រា ៥៩.-**

ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការពិនិត្យ តាមដានការអនុវត្តន៍របស់ ក្រុមប្រឹក្សា និង រដ្ឋបាលឃុំ សង្កាត់ ។ មេឃុំ ចៅសង្កាត់ត្រូវធានាថា:

១- រាល់ពត៌មានស្តីពីសកម្មភាព និងគណនីរបស់ឃុំ សង្កាត់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ

២- ការទទួលមតិសាធារណៈនិងការពិគ្រោះយោបល់ត្រូវបានប្រព្រឹត្តទៅក្នុងដំណើរការរៀបចំថវិកា

៣- ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និង អញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**មាត្រា ៦០.-**

មេឃុំ ចៅសង្កាត់ ក្នុងឋានៈជាអាណាប័ក គណនេយ្យករឃុំ សង្កាត់ និងបុគ្គលទាំងឡាយដែលចូលរួមនៅក្នុងដំណើរការអនុវត្តន៍ថវិកាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់សកម្មភាពរំលោភទៅលើវិន័យថវិកា ដូចខាងក្រោម:

១- ការសន្យាចំណាយ លើសឥណទានថវិកាដែលបានទទួលការអនុញ្ញាត

២- រាល់អំពើដែលជាកម្មវត្ថុសំរាប់បង្កើនទឹកប្រាក់ឥណទានថវិកាដែលបានទទួលការអនុញ្ញាតដោយធនធានពិសេសក្រៅពីករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ជាជាធរមាន

៣- រាល់កំហុសធ្ងន់ធ្ងរដែលនាំអោយមានការខាតបង់ប្រាក់កាសដល់ហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិ របស់ឃុំ សង្កាត់ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៦១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំស្តីពីការអនុវត្តន៍ជាក់ស្តែង រាល់កិច្ចការទាំងឡាយ ដូចមានចែងនៅក្នុងជំពូកទី២ ដល់ជំពូកទី៧ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ស ខេង យូ ហុកគ្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ៣

# អនុក្រឹត្យ លេខ២៦៤ អនក្រ.បក ចុះថ្ងៃទី01 ខែតុលាឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

# ឧបសម្ព័ន្ធ៤

## តារាងចំនួនឃុំ សង្កាត់ ក្រុង ស្រុក រាជធានី ខេត្ត និង សមាជិកក្រុមប្រឹក្សាសម្រាប់ បោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រ.ក/លេខ 02.017/14 គ.ជ.ប/អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ២០១៤

# តារាងចំនួនឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងសមាជិកក្រុមប្រឹក្សា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤

| ល.រ | ឈ្មោះ រាជធានី ខេត្ត | ចំនួន ឃុំ សង្កាត់ | សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ | ចំនួន ក្រុង ស្រុក ខណ្ឌ | សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត |
|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 65 | 515 | 9 | 135 | 17 |
| 02 | បាត់ដំបង | 102 | 814 | 14 | 216 | 19 |
| 03 | កំពង់ចាម | 109 | 817 | 10 | 182 | 21 |
| 04 | កំពង់ឆ្នាំង | 69 | 419 | 8 | 122 | 15 |
| 05 | កំពង់ស្ពឺ | 87 | 609 | 8 | 136 | 17 |
| 06 | កំពង់ធំ | 81 | 577 | 8 | 132 | 17 |
| 07 | កំពត | 93 | 561 | 8 | 128 | 17 |
| 08 | កណ្ដាល | 127 | 915 | 11 | 197 | 21 |
| 09 | កោះកុង | 29 | 167 | 7 | 63 | 13 |
| 10 | ក្រចេះ | 46 | 282 | 6 | 88 | 15 |
| 11 | មណ្ឌលគីរី | 21 | 107 | 5 | 39 | 9 |
| 12 | ភ្នំពេញ | 96 | 810 | 12 | 216 | 21 |
| 13 | ព្រះវិហារ | 51 | 333 | 8 | 86 | 13 |
| 14 | ព្រៃវែង | 116 | 892 | 13 | 213 | 19 |
| 15 | ពោធិ៍សាត់ | 49 | 343 | 6 | 88 | 15 |
| 16 | រតនគីរី | 50 | 260 | 9 | 81 | 13 |
| 17 | សៀមរាប | 100 | 668 | 12 | 180 | 19 |
| 18 | ព្រះសីហនុ | 27 | 169 | 4 | 50 | 15 |
| 19 | ស្ទឹងត្រែង | 34 | 176 | 5 | 53 | 13 |
| 20 | ស្វាយរៀង | 80 | 518 | 8 | 122 | 15 |
| 21 | តាកែវ | 100 | 736 | 10 | 172 | 19 |
| 22 | កែប | 5 | 31 | 2 | 18 | 9 |
| 23 | ប៉ៃលិន | 8 | 52 | 2 | 26 | 9 |
| 24 | ឧត្ដរមានជ័យ | 24 | 152 | 5 | 65 | 13 |
| 25 | ត្បូងឃ្មុំ | 64 | 536 | 7 | 123 | 19 |
| សរុបទូទាំងប្រទេស | | 1,633 | 11,459 | 197 | 2,931 | 393 |

# ឧបសម្ព័ន្ធ៥

# តម្លៃសេវារដ្ឋបាលថ្នាក់ក្រោមជាតិ នៅសង្កាត់ផ្សារដើមថ្កូវ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងតម្លៃសេវារដ្ឋបាលសង្កាត់

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| **១-ការងារអត្រានុកូលដ្ឋាន** | | | | | |
| 1 | សំបុត្រកំណើត | មិនយកកម្រៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 2 | សំបុត្របញ្ជាក់កំណើត(បិទតែមប្រ៍លើពាក្យសុំ) | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 3 | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 4 | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍(បិទតែមប្រ៍លើពាក្យសុំ) | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 5 | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ) | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 6 | សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេស ជាមួយពលរដ្ឋខ្មែរ) | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 7 | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 8 | សំបុត្រមរណៈភាព(ក្នុងរយៈពេល១៥ថ្ងៃ) | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 9 | សំបុត្រមរណៈភាព(ហួសរយៈពេល ១៥ថ្ងៃ ក្នុងឆ្នាំ) | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 10 | សេចក្តីចម្លងសំបុត្រមរណៈភាព | 0 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| **២-ការងារចេញលិខិតអនុញ្ញាត** | | | | | |
| 1 | លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ | 0 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| 2 | លិខិតបញ្ជាក់ទីលំនៅ | 0 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| 3 | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | 4 000 | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ ច្បាប់ |
| 4 | លិខិតបញ្ជាក់ពីប្រវត្តិជីវិត | 10 000 | ៧ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| 5 | លិខិតបញ្ជាក់ទាយាទ | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| 6 | លិខិតបញ្ជាក់កិរិយាមាយាទ | 5 000 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| 7 | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | 0 | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| 8 | លិខិតបញ្ជាក់តបណ្តាញអគ្គិសនី | 5 000 | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| 9 | លិខិតបញ្ជាក់តបណ្តាញទឹកស្អាត | 5 000 | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| 10 | លិខិតបញ្ជាក់ជួលដី ផ្ទះ គូប យានជំនិះ | 10 000 | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ សន្លឹក |
| 11 | លិខិតផ្ទះជួលបន្ទប់ស្នាក់នៅ | 5 000 | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| 12 | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត(ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ | 5 000 | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |

✓ បញ្ជាក់៖ - ពាក្យស្នើសុំសេវារដ្ឋបាល និងត្រូវផ្តល់ជូនដោយមិនគិតកម្រៃ។